**មេរៀនទី៨**

# ល្បឿនប្រតិកម្ម

## ១ ល្បឿនប្រតិកម្ម

### ១.១ ប្រតិកម្មលឿន និងប្រតិកម្មយឺត

ប្រតិកម្មមួយចំនួនប្រព្រឹត្តទៅលឿន ហើយប្រតិកម្មមួយចំនួនទៀតប្រព្រឹត្តទៅយឺត។ ចូរពិនិត្យមើលឧទាហរណ៍ទាំងនេះ ÷



នៅពេលដែលគេបន្តក់សូលុយស្យុងប្រាក់នីត្រាត ទៅលើសូលុយស្យុងសូដ្យូមក្លរួនោះកករពណ៌សនៃប្រាក់ក្លរួនឹងកើតឡើងភ្លាម។ នេះជា**ប្រតិកម្មលឿន**មួយ។



ការឡើងរឹងនៃបាយអរ ត្រូវការចំណាយពេលពីរបីថ្ងៃ។ នេះជាប្រតិកម្មយឺតមួយ។



ការឡើងច្រេះនៃដែកត្រូវការរយៈពេលយូរ។ នេះជាប្រតិកម្មយឺតបំផុត។

ការដឹងត្រឹមតែប្រតិកម្មលឿន ឬយឺតនោះវាមិនគ្រប់គ្រាន់ទេ។ *ឧទាហរណ៍* នៅក្នុងរោងចក្រមួយដែលផលិតផលិតផលចេញពីធាតុគីមី វិស្វករគីមីត្រូវតែដឹងឱ្យជាក់លាក់ថាតើប្រតិកម្មនោះកើតឡើងលឿនប៉ុណ្ណា ហើយតើវាត្រូវការរយៈពេលប៉ុន្មានដើម្បីឱ្យប្រតិកម្មមួយប្រព្រឹត្តទៅសព្វ ឬយើងអាចនិយាយបានម្យ៉ាងទៀតថាគេត្រូវ ការដឹងពី**ល្បឿនប្រតិកម្ម**។

### ១.២ ល្បឿន

ល្បឿនគឺជារង្វាស់ដើម្បីឱ្យដឹងថាតើអ្វីមួយប្រព្រឹត្តទៅលឿន ឬយឺតយ៉ាងដូចម្ដេច។

*ឧទាហរណ៍* យន្តហោះអាចហោះហើរបានចម្ងាយ 2000 km ក្នុង 1ម៉ោង។ វាមានល្បឿន 2000 km ក្នុង 1ម៉ោង។

ម៉ាស៊ីនថតចម្លងមួយ អាចថតចម្លងបាន 30 សន្លឹកក្នុង 1នាទី។ វាមានល្បឿន 30 សន្លឹកក្នុង 1នាទី។

តាមឧទាហរណ៍ខាងលើនេះ យើងអាចដឹងថា *ល្បឿនគឺជារង្វាស់នៃបម្លាស់ប្ដូរដែលប្រព្រឹត្តទៅក្នុងមួយខ្នាតពេល។*

យើងអាចប្រើខ្នាតពេលសមស្របណាមួយក៏បានដូចជាវិនាទី នាទី ម៉ោង ឬថ្ងៃ ។

## ១.៣ ល្បឿនប្រតិកម្មគីមី



នៅពេលគេដាក់ស័ង្កសីទៅក្នុង សូលុយស្យុង អាស៊ីតស៊ុលផួរិចរាវ វាមានប្រតិកម្មជាមួយគ្នា ។ ស័ង្កសីបាត់បង់បន្តិចម្តង ហើយគេសង្កេត ឃើញមានពពុះភាយឡើង ។



បន្តិចក្រោយមក ពពុះឧស្ម័នភាយឡើងយឺត១ ។ សកម្មភាពនៃប្រតិកម្មនេះថយចុះ ។



ទីបំផុត គេពុំឃើញមានពពុះឧស្ម័នភាយឡើងទៀតទេ ។ ប្រតិកម្មនេះ បានបញ្ចប់ព្រោះអាស៊ីតចូលរួមប្រតិកម្មអស់ ហើយមានស័ង្កសីមួយចំនួននៅសល់ក្រោយ ប្រតិកម្ម ។

ក្នុងឧទាហរណ៍នេះ ឧស្ម័នដែលភាយឡើងនោះគឺអ៊ីដ្រូសែន ។ សមីការតាងប្រតិកម្មនេះគឺ ÷

សង្កសី + អាស៊ីតស៊ុលផួរិច $\longrightarrow$ សង្កសីស៊ុលផាត + អ៊ីដ្រូសែន

$$Zn(s) + H_2SO_4(aq) \longrightarrow ZnSO_4(aq) + H_2(g)$$

ស័ង្កសី និងអាស៊ីតស៊ុលផួរិចត្រូវបានបាត់បង់នៅក្នុងប្រតិកម្ម ។ ជាមួយគ្នានេះដែរមានការកកើតជាសារធាតុថ្មី ស័ង្កសី ស៊ុលផាត និងអ៊ីដ្រូសែន ។

យើងអាចវាស់ល្បឿនប្រតិកម្មដោយការវាស់បរិមាណណាមួយក៏បានក្នុងចំណោមបរិមាណខាង ក្រោម ÷

- បរិមាណស័ង្កសីដែលប្រើអស់ក្នុងរយៈពេលមួយនាទី ឬ
- បរិមាណអាស៊ីតស៊ុលផួរិចដែលប្រើអស់ក្នុងរយៈពេលមួយនាទី ឬ
- បរិមាណស័ង្កសីស៊ុលផាតដែលកកើតក្នុងរយៈពេលមួយនាទី ឬ
- បរិមាណអ៊ីដ្រូសែនដែលកកើតក្នុងរយៈពេលមួយនាទី

ចំពោះប្រតិកម្មនេះ ការវាស់មាឌអ៊ីដ្រូសែនដែលកកើតក្នុងមួយនាទីមានភាពងាយស្រួលជាងគេ ។ យើងអាចត្រង និងវាស់មាឌអ៊ីដ្រូសែននៅពេលវាភាយឡើង ។

ជាទូទៅ ដើម្បីរកល្បឿនរបស់ប្រតិកម្មមួយយើងត្រូវ វាស់បរិមាណអង្គធាតុប្រតិករដែលប្រើអស់ ឬវាស់បរិមាណផលិតផលដែលកកើតក្នុងមួយខ្នាតពេលណាមួយ ។

**សំណួរ**

1. ខាងក្រោមនេះជាប្រតិកម្មមួយចំនួនដែលកើតមានឡើងនៅក្នុងគេហដ្ឋាន ។ ចូរតម្រៀបប្រតិកម្មនោះតាមលំដាប់ល្បឿនថយចុះ ( ប្រតិកម្មលឿនមុនគេ) ។

**ការឡើងស្វិតនៃថ្នាំលាបផ្ទះ ផ្លែឈើរលួយ ចំហេះចង្រ្កានហ្គាស ការដុតនំ និង ការឡើងច្រេះរបស់លោហៈ**

2. តើល្បឿននៃការធ្វើដំណើរមួយណាដែលយឺតជាងគេបំផុត?

ក- 5 km ក្នុងមួយវិនាទី

ខ- 20 km ក្នុងមួយនាទី

គ- 60 km ក្នុងមួយម៉ោង

3. ឧបមាថា យើងចង់វាស់ល្បឿននៃការបាត់បង់អស់របស់ស័ង្កសីនៅក្នុងប្រតិកម្មខាងលើ តើរង្វាស់មួយណាក្នុងចំណោមរង្វាស់ខាងក្រោមនេះមានភាពសមស្រប?

ក- គិតជាលីត្រ ក្នុងមួយនាទី

ខ- គិតជាក្រាមក្នុងមួយនាទី

គ- គិតជាសង់ទីម៉ែតក្នុងមួយនាទី ។ ចូរពន្យល់នូវជម្រើសរបស់អ្នក?

4. ដែកមានប្រតិកម្មជាមួយអាស៊ីតស៊ុលផួរិច តាមសមីការដូចខាងក្រោមនេះ ។

$$Fe\,(s) + H_2SO_4\,(aq) \longrightarrow FeSO_4\,(aq) + H_2\,(g)$$

ក. ចូរសរសេរសមីការប្រតិកម្មនេះជាអក្សរ

ខ. ចូរសរសេរវិធីបួនយ៉ាងដែលយើងអាចប្រើដើម្បីវាស់ល្បឿនរបស់ប្រតិកម្មនេះបាន ។

# ២ ការវាស់ល្បឿនប្រតិកម្ម

## ២.១ ប្រតិកម្មបង្កើតឧស្ម័ន

យើងអាចវាស់ល្បឿនប្រតិកម្មដោយរកបរិមាណ **អង្គធាតុប្រតិករ** ដែលប្រើអស់ ឬបរិមាណ **ផលិតផល** ដែលកកើតក្នុងមួយខ្នាតពេលណាមួយ ។

*ឧទាហរណ៍* ម៉ាញេស្យូម + អាស៊ីតក្លរីឌ្រិច ⟶ ម៉ាញេស្យូមក្លរួ + អ៊ីដ្រូសែន

$$Mg\,(s) + 2\,HCl\,(aq) \longrightarrow MgCl_2\,(aq) + H_2\,(g)$$

ករណីនេះអ៊ីដ្រូសែន គឺជាសារធាតុដែលយើងមានភាពងាយស្រួលក្នុងការវាស់ ។ នេះដោយសារអ៊ីដ្រូសែនជាឧស្ម័នតែមួយគត់នៅក្នុងប្រតិកម្ម ។ ឧស្ម័ននេះភាយចេញមកជាពពុះ ហើយយើងអាចត្រងពពុះនេះបានដោយប្រើ **សឺរ៉ាំង** ដែលយើងអាចវាស់មាឌវាបាន ។

*សំគាល់* ប្រតិកម្មខ្លះលឿនណាស់ ដែលធ្វើឱ្យយើងមានការលំបាកក្នុងការវាស់ល្បឿនរបស់វា ។ ដូចជាការផ្ទុះអណ្តូងរ៉ែ ការផ្ទុះគ្រាប់បែក ការផ្ទុះបំពង់ឧស្ម័ន ។

## ២.២ វិធីសាស្ត្រក្នុងការវាស់

ដំបូងយើងត្រូវខាត់ម៉ាញ៉េស្យូមដោយប្រើក្រដាសខាត់ដើម្បីឱ្យអស់ធាតុមិនសុទ្ធ ។ យើងដាក់អាស៊ីតក្លរីឌ្រិចទៅក្នុងកែវ បន្ទាប់មកទម្លាក់ម៉ាញ៉េស្យូម រួចចុកឆ្នុកកៅស៊ូដែលមានភ្ជាប់ជាមួយនឹងសឺរ៉ាំងយ៉ាងរហ័ស ជាមួយគ្នានេះដែរត្រូវចាប់ផ្តើមវាស់រយៈពេលប្រតិកម្មដោយប្រើនាឡិកាក្រិត ។ ឧស្ម័នអ៊ីដ្រូសែនចាប់ផ្តើមភាយឡើង ចូលទៅក្នុងសឺរ៉ាំងដោយរុញបណ្តូលសឺរ៉ាំងឱ្យចេញថយក្រោយ ។






ដំបូងបណ្តូលនៅចំនុចសូន្យ ។ យើងមិនទាន់បានប្រមូលឧស្ម័ននៅឡើយ ។

ពេលដែលបណ្តូលសឺរ៉ាំងរំកិលមកត្រឹមលេខ 20 $cm^3$ មានន័យថា មាឌឧស្ម័ន ដែលត្រងបានមាន 20 $cm^3$ ។

មាឌរបស់ឧស្ម័ននៅក្នុងស៊ីរ៉ាំងត្រូវបានគេកត់ត្រា30វិនាទីម្តង ។ តើយើងសំគាល់យ៉ាងដូចម្តេចទើបដឹងថាប្រតិកម្មនេះប្រព្រឹត្តទៅចប់ ?

**លទ្ធផល**

| **ពេល** (**វិនាទី**) | 0 | 30 | 60 | 90 | 120 | 150 | 180 | 210 | 240 | 270 | 300 | 330 | 360 | 390 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **មាឌឧស្ម័ន** ($cm^3$) | 0 | 8 | 14 | 20 | 25 | 29 | 33 | 36 | 38 | 39 | 40 | 40 | 40 | 40 |

តាមរយៈលទ្ធផលនេះ យើងអាចគូក្រាភិចដូចរូបខាងក្រោមនេះ ។



*សំគាល់*

- នៅនាទី ទីមួយ អ៊ីដ្រូសែនកកើតបានចំនួន 14 $cm^3$ ដូចនេះល្បឿននៅនាទីទីមួយគឺ 14 $cm^3$ ក្នុងមួយនាទី ។ នៅនាទី ទី២ អ៊ីដ្រូសែនករកើតបាន 11 $cm^3$ (25 - 14 =11) ដូចនេះល្បឿននៅក្នុងនាទីទីពីរ គឺ 11 $cm^3$ ក្នុងមួយ នាទី។ ដូច្នេះយើងសង្កេតឃើញថា ល្បឿនប្រតិកម្មថយចុះ កាលណារយៈពេលកើនឡើង។ *ល្បឿនប្រតិកម្មប្រែប្រួលរហូត លឿននៅពេលចាប់ផ្ដើម ហើយកាន់តែយឺតទៅៗនៅពេលដែលប្រតិកម្មចេះតែបន្ត។*
- ប្រតិកម្មប្រព្រឹត្តទៅលឿនបំផុតនៅនាទីទីមួយ ហើយខ្សែកោងចោតបំផុតនៅពេលនេះ។ ខ្សែកោងនេះចាប់ផ្ដើមរាបទៅៗ ព្រោះល្បឿនប្រតិកម្មថយចុះ ។ *កាលណាល្បឿនកាន់តែលឿន នោះខ្សែកោងកាន់តែចោត* ។
- បន្ទាប់ពីរយៈពេល 5 នាទីមក គ្មានអ៊ីដ្រូសែនកកើតទៀតទេ ដូចនេះមាឌរបស់វាក៏មិនប្រែប្រួលដែរ មានន័យថាប្រតិកម្មបានបញ្ចប់ ហើយខ្សែកោងប្រែជារាបដូចខ្សែត្រង់វិញ។ *នៅពេលដែលប្រតិកម្មចប់ នោះខ្សែកោងនឹងមានរាងដូចជាបន្ទាត់វិញ ។*
- នៅក្នុងប្រតិកម្មទាំងមូលអ៊ីដ្រូសែនកកើតបាន 40 $cm^3$ ក្នុងរយៈពេល 5 នាទី ។




$$\text{ល្បឿនមធ្យមរបស់ប្រតិកម្ម} = \frac{\text{មាឌអ៊ីដ្រូសែនសរុប}}{\text{រយៈពេលសរុបរបស់ប្រតិកម្ម}}$$

$$= \frac{40\,cm^3}{5\,mn} = 8\,cm^3$$ អ៊ីដ្រូសែនក្នុងមួយនាទី (8 $cm^3$/mn)

***ចំណាំ*** វិធីសាស្ត្រវាស់ល្បឿនប្រតិកម្មនេះអាចប្រើប្រាស់បានគ្រប់ប្រតិកម្មដែលមានផលិតផលមួយជាឧស្ម័ន ។

**សំណួរ**

1. ចំពោះការពិសោធនេះ ចូរពន្យល់ថាហេតុអ្វីបានជា

   ក. ឆ្នុកកៅស៊ូត្រូវចុកឱ្យរប៉ស?

   ខ. ត្រូវខាត់ម៉ាញេស្យូមជាមុន ?

   គ. ចាប់ផ្ដើមចុចនាឡិកាក្រិតភ្លាមនៅពេលដាក់អង្គធាតុប្រតិករឱ្យមានប្រតិកម្មជាមួយគ្នា ?
2. តាមរយៈក្រាបខាងលើនេះ តើមានភស្តុតាងអ្វីដែលបញ្ជាក់ថាប្រតិកម្មបានបញ្ចប់ ?
3. ចូរក្រឡេកមើលក្រាបខាងលើនេះ ។

ក. តើអ៊ីដ្រូសែនកកើតបានប៉ុន្មាននៅរយៈពេល 150 វិនាទី និង នៅ 270 វិនាទី?

ខ. តើយើងត្រូវការរយៈពេលប៉ុន្មាន ដើម្បីផលិតបរិមាណឧស្ម័នអ៊ីដ្រូសែន

(i) 10 $cm^3$

(ii) 20$cm^3$

4. តើប្រតិកម្មនេះមានល្បឿនប៉ុន្មាននៅ ÷

ក. នាទីទីបួន

ខ. នាទីទីប្រាំ

# ៣ បំលាស់ប្តូរល្បឿនប្រតិកម្ម

## ៣.១ ឥទ្ធិពលនៃកំហាប់

យើងអាចធ្វើឱ្យប្រតិកម្មមួយលឿន ឬយឺត ដោយគ្រាន់តែដូរ **កំហាប់** របស់អង្គធាតុប្រតិករ។ ឧបមាថាប្រតិកម្មរវាងម៉ាញេស្យូម និងអាស៊ីតក្លរីឌ្រិចលើសត្រូវបានគេរៀបចំធ្វើចំនួនពីរដងដូចខាងក្រោម (A និងB។ អ្វីៗទាំងអស់ត្រូវបានគេរក្សាឱ្យនៅដដែល *លើកលែង* តែកំហាប់របស់អាស៊ីត ។




អាស៊ីតនៅក្នុងប្រតិកម្ម A មានកំហាប់ពីរដងនៃអាស៊ីតក្នុងប្រតិកម្ម B។ ក្រាភិចខាងក្រោមនេះ គឺជាលទ្ធផលនៃប្រតិកម្មទាំងពីរ។



*សំគាល់*

- ខ្សែកោង A ចោទជាងខ្សែកោង B ។ តាមរយៈខ្សែកោងនេះ យើងអាចនិយាយបានថា ប្រតិកម្ម A លឿនជាង ប្រតិកម្ម B ។
- ប្រតិកម្មនៅក្នុងពិសោធន៍ A ប្រើរយៈពេល 60 វិនាទី ហើយនៅក្នុងពិសោធន៍ B ប្រើរយៈពេល 120 វិនាទី ។
- ប្រតិកម្មទាំងពីរផលិតបានអ៊ីដ្រូសែន 60 $cm^3$ ដូចគ្នា។ ក្នុង A អ៊ីដ្រូសែនកកើតតែក្នុងរយៈពេល 60 វិនាទីប៉ុណ្ណោះ ដូចនេះល្បឿនមធ្យមរបស់វាគឺ 1 $cm^3$ក្នុងមួយវិនាទី (1 $cm^3/s$) ។ នៅក្នុង B អ៊ីដ្រូសែនកកើតក្នុងរយៈពេល 120 វិនាទី ដូចនេះល្បឿនមធ្យមនៃការកកើតអ៊ីដ្រូសែនគឺ 0.5 $cm^3$ ក្នុងមួយវិនាទី(0,5 $cm^3/s$) ។ ល្បឿនមធ្យមនៅក្នុង A ធំជាងពីរដងនៃល្បឿនមធ្យមក្នុង B ។

លទ្ធផលនេះបង្ហាញថា *ប្រតិកម្មមានល្បឿន កាន់តែលឿនកាលណាកំហាប់របស់អង្គធាតុប្រតិករត្រូវបានបង្កើន* ។ ចំពោះប្រតិកម្មខាងលើនេះ ល្បឿនប្រតិកម្មកើនឡើងពីរដងកាលណាយើងបង្កើនកំហាប់ចំនួនពីរដងដែរ ។

យើងអាចសំអាតស្នាមប្រឡាក់នេះ
ដោយសូលុយស្យុង ជម្រះក្អែល ។
កាលណាកំហាប់ របស់វាកាន់តែ
ខាប់នោះស្នាមប្រលាក់កាន់តែឆាប់ជ្រះ ។




## ៣.២ ឥទ្ធិពលសីតុណ្ហភាព

យើងក៏អាចធ្វើឱ្យប្រតិកម្មមួយលឿន ឬយឺតបានដែរដោយគ្រាន់តែធ្វើការផ្លាស់ប្តូរ **សីតុណ្ហភាព** របស់អង្គធាតុប្រតិករ ។ បើពេលគេលាយសូលុយស្យុងអាស៊ីតក្លរីឌ្រិចរាវជាមួយសូលុយស្យុងសូដ្យូមត្យូស៊ុលផាត គេនឹងឃើញកករពណ៌លឿងនៃស្ពាន់ធ័រកើតឡើង ។ យើងអាចសង្កេតល្បឿនប្រតិកម្មនេះតាមលំនាំដូចខាងក្រោម ÷

1. គូសសញ្ញាខ្វែងមួយនៅលើក្រដាសស
2. ដាក់កែវបេស៊ែដែលមានដាក់សូលុស្យុងសូដ្យូមត្យូស៊ុលផាតនៅលើក្រដាសដែលមានសញ្ញាខ្វែង។ សញ្ញាខ្វែងនេះអាចឱ្យយើងងាយស្រួលមើលឃើញពីលើតាមរយៈសូលុយស្យុង ។
3. ចុចនាឡិកាក្រិតដំណាលគ្នានៅពេលបន្ថែមអាស៊ីក្លរីឌ្រិចចូល ។សញ្ញាខ្វែងនឹងរលុបបាត់បន្តិចម្តងៗ ពេលដែលកករកើតមានឡើង ។
4. បញ្ឈប់នាឡិកាក្រិតខណៈពេលយើងមើលសញ្ញាខ្វែងលែងឃើញ ។

ការមើលពីខាងលើកែវបេស៊ែ ។



យើងត្រូវធ្វើពិសោធន៍នេះបួនទៅប្រាំដង ដោយរក្សាអ្វីៗឱ្យនៅដដែល ក្នុងពិសោធន៍មួយលើកៗប៉ុន្តែត្រូវធ្វើការផ្លាស់ប្តូរ **សីតុណ្ហភាព** ។

តារាងនេះ បង្ហាញពីលទ្ធផល

| សីតុណ្ហភាព $^{0}$C | 20 | 30 | 40 | 50 | 60 |
|---|---|---|---|---|---|
| រយៈពេលដែលសញ្ញាខ្វែងបាត់ (វិនាទី) | 200 | 125 | 50 | 33 | 24 |
| ស៊ីតុណ្ហភាពកាន់តែខ្ពស់ សញ្ញាខ្វែងរលប់បាត់កាន់តែឆាប់ | | | | | |

## ការប្រៀបធៀបល្បឿនរបស់ប្រតិកម្មទាំងនេះ

$$\text{ល្បឿនមធ្យម} = \frac{\text{ម៉ាសស្ពាន់ធ័រ (g)}}{\text{រយៈពេលករកើតស្ពាន់ធ័រ (s)}}$$

ម៉ាសស្ពាន់ធ័រចាំបាច់ដើម្បីធ្វើឱ្យយើងមើលសញ្ញាលែងឃើញមានបរិមាណស្មើគ្នាក្នុងពិសោធន៍នីមួយៗ ។

ឧបមាថាម៉ាសស្ពាន់ធ័រ 1g ដូចនេះ

នៅសីតុណ្ហភាព 20 $^{0}$C $= \frac{1}{200} g/s = 0,005$ g/s

នៅសីតុណ្ហភាព 40 $^{0}$C $= \frac{1}{50} g/s = 0.02\ g.s$

ដូចនេះ នៅសីតុណ្ហភាព 40 $^{0}$C ប្រតិកម្មនេះមានល្បឿន៤ដងលឿនជាងនៅ 20 $^{o}$C (4 × 0,005 = 0,02) ។

យើងមើលសញ្ញាខ្វែងលែងឃើញនៅពេលស្ពាន់ធ័រកកើតឡើងគ្រប់គ្រាន់ ។ ចូរកត់សំគាល់ថា វាប្រើអស់រយៈពេល 200 s នៅសីតុណ្ហភាព 20 $^{o}$C ប៉ុន្តែប្រើពេលអស់តែ 50 s ប៉ុណ្ណោះនៅសីតុណ្ហភាព 40 $^{o}$C ។ ដូចនេះ នៅសីតុណ្ហភាព 40 $^{o}$C ប្រតិកម្មកើតឡើងបួនដងលឿនជាងនៅ 20 $^{o}$C ។

*ប្រតិកម្មមួយប្រព្រឹត្តទៅកាន់តែលឿន កាលណាសីតុណ្ហភាពកាន់តែកើន ។ នៅពេលដែលគេបង្កើនសីតុណ្ហភាពត្រឹមតែ 10 $^{0}$C នោះល្បឿនកើនឡើងប្រហែលពីរដង ។*

*សំគាល់* សីតុណ្ហភាពទាបនៅក្នុងទូទឹកកក បានបន្ថយល្បឿនប្រតិកម្មបំបែក ។ យើងអាចរក្សាម្ហូបអាហារឱ្យនៅស្រស់បានយូរ ។

**សំណួរ**

1. ចូរពិនិត្យមើលក្រាបនៅទំព័រទី៦ ។
   ក. តើគេទទួលបានអ៊ីដ្រូសែនប៉ុន្មាននៅក្នុងពិសោធន៍ A និង B ក្រោយពីរយៈពេលពីរនាទីមក?
   ខ. តាមរាងរបស់ខ្សែកោង តើប្រតិកម្មណាមួយប្រព្រឹត្តទៅលឿនជាង ?
2. ថាហេតុអ្វីបានជាប្រតិកម្ម A និង B ផលិតបានបរិមាណអ៊ីដ្រូសែនស្មើគ្នា ? ចូរពន្យល់ ។
3. ចូរបំពេញនូវចន្លោះដូចតទៅនេះ ÷
   ប្រតិកម្មមួយប្រព្រឹត្តទៅ ................នៅពេលដែលកំហាប់របស់ ............ ត្រូវបានគេបង្កើន ។ ហើយវាក៏ .........................នៅពេលដែល .......................ត្រូវបានដំឡើង ។
4. ហេតុអ្វីបានជាសញ្ញាខ្វែងរលុបបាត់ នៅក្នុងពិសោធន៍ប្រតិកម្មរវាងអាស៊ីតក្លរីឌ្រិច និង សូដ្យូមត្យូស៊ុលផាត ?
5. តើល្បឿនរបស់ប្រតិកម្មមួយប្រែប្រួលដូចម្តេចនៅពេលដែលគេបន្ថយសីតុណ្ហភាព? ចូរប្រើហេតុផលនេះដើម្បីពន្យល់ថា ហេតុអ្វីបានជាគេទុកទឹកដោះគោក្នុងទូទឹកកក ។

## ៣.៣ ឥទ្ធិពលនៃផ្ទៃប៉ះ

ក្នុងប្រតិកម្មជាច្រើន មានអង្គធាតុប្រតិករមួយជាអង្គធាតុរឹង ។

*ឧទាហរណ៍* ប្រតិកម្មរវាងអាស៊ីតក្លរីឌ្រិច និង**កាល់ស្យូមកាបូណាត** ។

$$CaCO_3\,(s) + 2HCl\,(aq) \longrightarrow CaCl_2\,(aq) + CO_2\,(g) + H_2O\,(l)$$

យើងអាចវាស់ល្បឿនប្រតិកម្មនេះដោយប្រើឧបករណ៍ដូចរូបខាងស្តាំ ។

**ដំណើរការ**




1. ដាក់កាល់ស្យូមកាបូណាតទៅក្នុងកែវបាឡុង ។
2. បន្ថែមអាស៊ីតក្លរីឌ្រិច រួចថ្លឹងម៉ាសភ្លាម១ ហើយចាប់ផ្តើមចុចនាឡិកាក្រិតឱ្យដើរ ។
3. ចុកមាត់កែវដោយប្រើសំឡីដើម្បីការពារកុំឱ្យអង្គធាតុរាវខ្ទាតចេញ ។
4. កត់ត្រាម៉ាសជាប្រចាំរាល់មួយនាទីម្តងរហូតដល់ប្រតិកម្មចប់ ។

ដោយសារតែកាបូនឌីអុកស៊ីតអាចហើរចេញតាមរយៈសំឡីបាន ដូចនេះកែវរបស់យើងនឹងមានទម្ងន់ស្រាលទៅៗ ពេលប្រតិកម្មចេះតែប្រព្រឹត្តទៅ (វាជាឧស្ម័នដែលធ្ងន់ដូចនេះយើងត្រូវតែគិតម៉ាសដែលបាត់បង់)។ ដូចនេះយើងអាចកំណត់ល្បឿនប្រតិកម្មបានតាមរយៈម៉ាសរបស់ឧស្ម័នកាបូនិចដែលបាត់បង់នៅចន្លោះទៀងទាត់ណាមួយ។ យើងត្រូវធ្វើពិសោធនេះចំនួនពីរដង ដោយរក្សាអ្វីៗឱ្យនៅដដែល លើកលែងតែ**ផ្ទៃប៉ះ** របស់កាល់ស្យូមកាបូណាត ។



នៅក្នុងការពិសោធន៍ទី 1 គេប្រើដុំកាល់ស្យូមកាបូណាតជាដុំធំៗផ្ទៃប៉ះរបស់វា គឺជាផ្ទៃសរុបដែលប៉ះទៅនឹងអាស៊ីត។



ចំពោះពិសោធន៍ទី 2 យើងប្រើម៉ាសកាល់ស្យូមកាបូណាតដដែល ប៉ុន្តែជាដុំតូចៗ។ ដូចនេះផ្ទៃប៉ះរបស់វាធំជាង ។

**ក្រាបនៃលទ្ធផលពិសោធន៍ទាំងពីរខាងលើ**




## របៀបគូសក្រាប

- ដំបូងយើងត្រូវរកម៉ាសដែលបាត់នៅខណៈពេលផ្សេង
- ម៉ាសដែលបាត់នៅខណៈពេលណាមួយ = ម៉ាសនៅខណៈពេលចាប់ផ្តើម – ម៉ាសនៅខណៈពេលនោះ។
- បន្ទាប់មកយើង គូសក្រាបនៃម៉ាសដែលបាត់ជាអនុគមន៍ទៅនឹងរយៈពេល។

តាមរយៈក្រាប យើងអាចកត់សំគាល់ដូចខាងក្រោម ÷

1. ខ្សែកោងទី2 ចោតជាងខ្សែកោងទី1។ លក្ខណៈនេះបង្ហាញថា កាល់ស្យូមកាបូណាតដែលមានគ្រាប់តូចៗមានប្រតិកម្ម លឿនជាងកាលស្យូមកាបូណាតដែលមានគ្រាប់ធំៗ។
2. ក្នុងពិសោធន៍ទាំងពីរ ម៉ាសដែលបាត់សរុបស្មើគ្នា គឺ 2,0 g ឬយើងអាចនិយាយបានម្យ៉ាងទៀតថា ម៉ាសកាបូនឌីអុកស៊ីតកកើតបាន 2,0 g ដូចគ្នា។

3. ចំពោះកាល់ស្យូមកាបូណាតដែលមានដុំតូចៗ ប្រតិកម្មប្រព្រឹត្តទៅសព្វដោយប្រើអស់រយៈពេល4នាទី។ ចំណែកឯកាល់ស្យូមកាបូណាតដែលមានដុំធំៗ ប្រតិកម្មប្រព្រឹត្តទៅសព្វដោយប្រើអស់រយៈពេល6នាទី។ លទ្ធផលនេះបង្ហាញថា *"ល្បឿនប្រតិកម្មកើនឡើង កាលណាផ្ទៃប៉ះរបស់អង្គធាតុប្រតិកររឹងកាន់តែធំ។"*

## ៣.៤ ឥទ្ធិពលនៃកាតាលីករ

អ៊ីដ្រូសែនពែអុកស៊ីតគឺជាអង្គធាតុរាវថ្លា គ្មានពណ៌ និងមានរូបមន្ត $H_2O_2$។ វាអាចបំបែកដោយខ្លួនទៅជាអុកស៊ីសែន និងទឹក។

$$\text{អ៊ីដ្រូសែនពែអុកស៊ីត} \longrightarrow \text{អុកស៊ីសែន} + \text{ទឹក}$$
$$2H_2O_2(l) \longrightarrow 2H_2O(l) + O_2(g)$$

យើងអាចតាមដានល្បឿនប្រតិកម្មតរយៈការត្រងយកឧស្ម័នអុកស៊ីសែន។




ប្រតិកម្មនេះប្រព្រឹត្តទៅយឺតណាស់។ យើងត្រូវចំណាយពេលប្រហែល 500 ថ្ងៃដើម្បីត្រងយកអុកស៊ីសែន 50 $cm^3$។

ប្រសិនបើគេបន្ថែមម៉ង់កាណែស IV អុកស៊ីត 1 g នោះប្រតិកម្មប្រព្រឹត្តទៅលឿន។ យើងអាចត្រងយកអុកស៊ីសែន ចំនួន 50 $cm^3$ តែក្នុងរយៈពេលពីរបីនាទី ប៉ុណ្ណោះ។

ក្រោយពីប្រតិកម្មប្រព្រឹត្តទៅចប់យើងអាចប្រមូលម្សៅពណ៌ខ្មៅវិញបាន ដោយការច្រោះ។ បន្ទាប់ មកយើងសម្ងួត ថ្លឹង និងធ្វើតេស្តឡើងវិញ។ យើងឃើញថា វានៅតែជា $MnO_2$ ដែលមានម៉ាស 1 g ដដែល។

ម៉ង់កាណែស IV អុកស៊ីតបង្កើនល្បឿនប្រតិកម្ម ហើយក្រោយពេលប្រតិកម្មវាមិនមានបាត់បង់អ្វីឡើយ។ នៅក្នុងប្រតិកម្មនេះគេហៅវាថា **កាតាលីករ**។

**កាតាលីករ** *គឺជាសារធាតុដែលធ្វើឱ្យមានការប្រែប្រួលដល់ល្បឿនប្រតិកម្មគីមី ប៉ុន្តែវានៅតែរក្សាលក្ខណៈដើមដដែលក្រោយពីប្រតិកម្មចប់។*

គេបានរកឃើញកាតាលីករជាច្រើនសម្រាប់ប្រតិកម្មគីមី។ កាតាលីករភាគច្រើនជាលោហៈឆ្លង ឬសមាសធាតុរបស់លោហៈឆ្លង។ ឧទាហរណ៍ ដែកអាចពន្លឿនប្រតិកម្មរវាងអាសូត និងអ៊ីដ្រូសែនក្នុងការផលិតអាម៉ូញាក់។ ក្រៅពីនេះនៅមានកាតាលីករជីវៈជាច្រើនដែលគេហៅថា **អង់ស៊ីម** ។ ឧទាហរណ៍ ក្រពេញរំលាយអាហាររួមមានអង់ស៊ីមដែលអាចពន្លឿនការរំលាយអាហាររបស់យើង ។

**សំណួរ**

1. សំណួរនេះទាក់ទងទៅនឹងក្រាបនៅទំព័រទី១០ ។ ចំពោះពិសោធន៍នីមួយៗ ចូរគណនា ៖

   ក. ម៉ាសដែលបាត់នៅនាទីទីមួយ ។

   ខ. ម៉ាសកាបូនឌីអុកស៊ីតកកើតនៅនាទីទីមួយ ។

   គ. ល្បឿនមធ្យមនៃការកកើតឧស្ម័នកាបូនិចក្នុងពិសោធន៍នីមួយៗ ។

2. ដូចម្តេចដែលហៅថាកាតាលីករ? ចូរឱ្យឧទាហរណ៍ប្រតិកម្មគីមីចំនួនពីរ ដោយបញ្ជាក់ពីកាតាលីកររបស់វា ។

3. ចូរពិនិត្យមើលប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ។ តើអ្នកអាចបង្ហាញបានយ៉ាងដូចម្តេច ៖

   ក. ប្រតិកម្មប្រព្រឹត្តទៅលឿនជាងមុនប្រសិនបើគេប្រើកាតាលីករច្រើនជាង 1 g?

   ខ. កាតាលីករមិនបាត់បង់ទៅណាទេបន្ទាប់ពីប្រតិកម្ម?

# ៤ បំណកស្រាយល្បឿនប្រតិកម្ម

## ៤.១ ការពិនិត្យមើលឱ្យច្បាស់នៅលើប្រតិកម្មមួយ

ម៉ាញ៉េស្យូម និងអាស៊ីតក្លរីឌ្រិចរាវមានអំពើជាមួយគ្នាតាមសមីការដូចខាងក្រោម ៖

ម៉ាញ៉េស្យូម + អាស៊ីតក្លរីឌ្រិច ⟶ ម៉ាញ៉េស្យូមក្លរួ + អ៊ីដ្រូសែន

$$Mg\,(s) + 2\,HCl\,(aq) \longrightarrow MgCl_2\,(aq) + H_2\,(g)$$

ដើម្បីឱ្យភាគល្អិតម៉ាញ៉េស្យូម និងអាស៊ីតក្លរីឌ្រិចមានអំពើជាមួយគ្នាលុះត្រាតែ ៖

- អង្គធាតុប្រតិករទាំងពីរទង្គិចគ្នា ។
- ការទង្គិចគ្នានេះត្រូវមានថាមពលគ្រប់គ្រាន់ ។

បាតុភូតនេះអាចពន្យល់បានតាមរយៈរូបខាងក្រោម ។




ភាគល្អិតរបស់អង្គធាតុរាវធ្វើចលនាជុំវិញជានិរន្តរ ។ ក្នុងករណីនេះភាគល្អិតរបស់អាស៊ីតប៉ះជាមួយនឹងភាគល្អិតរបស់អាតូមម៉ាញ៉េស្យូម ។

ប្រសិនបើការទាទានថាមពល គ្រប់គ្រាន់ នោះប្រតិកម្មនឹងកើតមាន ហើយ ម៉ាញ៉េស្យូមក្លរួ និង អ៊ីដ្រូសែន កកើតឡើង ។

ប្រសិនបើការទង្គិចគ្មានថាមពលគ្រប់គ្រាន់ នោះប្រតិកម្មមិនកើតមានទេ ហើយភាគល្អិតអាស៊ីតត្រូវខ្ទាតចេញវិញ ។

ប្រសិនបើមានទង្គិចប្រសិទ្ធជាច្រើនក្នុងនាទីណាមួយ នេះឧស្ម័នអ៊ីដ្រូសែនភាយឡើងក៏ច្រើនដែរនៅក្នុងនាទីនោះ។ម្យ៉ាងទៀតយើងអាចនិយាយបានថា ប្រតិកម្មប្រព្រឹត្តទៅលឿន (ល្បឿនប្រតិកម្មលឿន)។ ប្រសិនបើពុំមានទង្គិចប្រសិទ្ធជាច្រើនទេ នោះល្បឿនរបស់វាក៏យឺតដែរ។ ដូច្នេះ *ល្បឿនប្រតិកម្មមួយអាស្រ័យនឹងចំនួនទង្គិចប្រសិទ្ធ ក្នុងរយៈពេលកំណត់ណាមួយ។*

*សំគាល់* នៅក្នុងទង្គិចប្រសិទ្ធ ÷

- សម្ព័ន្ធចាស់ត្រូវបានផ្តាច់ (ត្រូវការថាមពល)។
- សម្ព័ន្ធថ្មីត្រូវបានបង្កើតឡើង (បញ្ចេញថាមពល)។

## ៤.២ បំលាស់ប្តូរល្បឿនប្រតិកម្ម

ហេតុអ្វីបានជាល្បឿនប្រតិកម្មកើនឡើង កាលណាកំហាប់អង្គធាតុប្រតិករកើន?

ប្រសិនបើកំហាប់របស់អាស៊ីតកើនឡើង នោះប្រតិកម្មនឹងប្រព្រឹត្តទៅលឿនជាងមុន។ យើងអាចពន្យល់បាតុភូតនេះបានយ៉ាងងាយស្រួលដូចរូបខាងក្រោម។




នៅក្នុងអាស៊ីតរាវ ភាគល្អិតរបស់អាស៊ីតមានតិចតួចប៉ុណ្ណោះ។ មានន័យថា ឱកាសនៃការប៉ះគ្នាមានតិចតួចណាស់។



បើអាស៊ីតមានកំហាប់ខាប់ជាងមុន មានន័យថា មានភាគល្អិតអាស៊ីតច្រើនជាងមុន។ ករណីនេះឱកាសនៃទង្គិចប្រសិទ្ធមានក៏មានច្រើនជាងមុនដែរ។

ដូច្នេះ *កាលណាទង្គិចប្រសិទ្ធកាន់តែច្រើន នោះល្បឿនប្រតិកម្មកាន់តែលឿន។*

គំនិតនេះក៏អាចពន្យល់បានពីមូលហេតុដែលប្រតិកម្មរវាងម៉ាញេស្យូម និងអាស៊ីតតែយឺតទៅៗកាលណារយៈពេលកាន់តែកើន។




នៅចំនុចផ្តើម មានភាគល្អិតអាស៊ីតនិងម៉ាញេស្យូមជាច្រើន។ ប៉ុន្តែភាគល្អិតទាំងនេះបាត់បង់នៅពេលដែលទង្គិចប្រសិទ្ធកើតមាន។



មួយរយៈក្រោយមក អាតូមម៉ាញេស្យូមនៅសល់កាន់តែតិចតួច ហើយ អាស៊ីតក៏មានកំហាប់កាន់តែតូចដែរ ។ ដូចនេះប្រតិកម្មប្រព្រឹត្តទៅកាន់តែ យឺត ។




មានន័យថា ខ្សែកោងតាងប្រតិកម្មកាន់តែរាបទៅៗ កាលណារយៈពេលកាន់តែកើន ។

*សំគាល់* ប្រតិកម្មរវាងឧស្ម័ន និងឧស្ម័ន ÷

- ការបង្កើនសម្ពាធទៅលើអង្គធាតុប្រតិករពីរដែលជាឧស្ម័ន មានឥទ្ធិពលដូចនឹងការបង្កើនកំហាប់ដែរ ។ មានន័យថា យើងបណ្ណែនម៉ូលេគុលឧស្ម័នទៅក្នុងលំហណាមួយ ។
- កាលណាចំនួនម៉ូលេគុលឧស្ម័ននៅក្នុងលំហណាមួយកាន់តែច្រើន នោះឱកាសនៃទង្គិចប្រសិទ្ធក៏កាន់តែច្រើនដែរ ។

ដូចនេះ *ប្រសិនបើសម្ពាធកើនឡើង នោះល្បឿនប្រតិកម្មក៏កើនដែរ ចំពោះអង្គធាតុប្រតិករជាឧស្ម័ន ។*

ហេតុអ្វីបានជាល្បឿនប្រតិកម្មកើនឡើង កាលណាសីតុណ្ហភាពកើន?

នៅសីតុណ្ហភាពទាប ភាគល្អិតរបស់អង្គធាតុប្រតិករពុំមានថាមពលខ្លាំងទេ ប៉ុន្តែនៅពេលគេដុតកម្តៅសារធាតុ ទាំងនោះ ភាគល្អិតនឹងស្រូបយកថាមពលដែលជាហេតុនាំឱ្យវាមានចលនាកាន់តែលឿន ហើយទង្គិចកាន់តែញាប់ ។ កាលណាការទង្គិចកាន់តែមានថាមពលខ្លាំង នោះទង្គិចប្រសិទ្ធក៏កាន់តែមានច្រើនដែរ ។ ដូចនេះល្បឿនរបស់ប្រតិកម្មក៏ កើនឡើងដែរ ។

ហេតុអ្វីបានជាល្បឿនប្រតិកម្មកើនឡើង កាលណាផ្ទៃប៉ះកាន់តែធំ?

ប្រតិកម្មរវាងម៉ាញេស្យូម និងអាស៊ីតមានល្បឿន លឿននៅពេលប្រតិកម្មយើងប្រើម៉ាញេស្យូមជាម្សៅ ។




ភាគល្អិតអាស៊ីតអាចទង្គិចតែជាមួយអាតូមម៉ាញេស្យូមនៅ ខាងក្រៅប៉ុណ្ណោះ ។



កាលណាលោហៈស្ថិតក្នុងភាពជាម្សៅ អាតូមជាច្រើន ងាយប៉ះជាមួយភាគល្អិតអាស៊ីត ។ ដូចនេះវាមាន ទង្គិចប្រសិទ្ធកាន់តែច្រើន ។

ហេតុអ្វីបានជាកាតាលីករបង្កើនល្បឿនប្រតិកម្ម?

យើងអាចបង្កើនល្បឿនប្រតិកម្មមួយចំនួនដោយប្រើកាតាលីករ។ *ពេលមានវត្តមានកាតាលីករ ទង្គិចប្រសិទ្ធត្រូវការថាមពលតិច*។ ជាលទ្ធផលទង្គិចប្រសិទ្ធកើតមានកាន់តែច្រើន ដែលជាហេតុនាំឱ្យប្រតិកម្មប្រព្រឹត្តកាន់តែលឿន។ កាតាលីករមានសារៈសំខាន់ណាស់នៅក្នុងឧស្សាហកម្ម ព្រោះវាអាចបង្កើនល្បឿនប្រតិកម្ម ទោះជាស្ថិតនៅសីតុណ្ហភាពទាបក៏ដោយ ដូចនេះមានតាមរយៈការប្រើកាតាលីករ អាចឱ្យគេប្រើឥន្ទនៈអស់តិច និងចំណេញពេលវេលា។

**សំណួរ**

1. ចូរបំពេញឃ្លាខាងក្រោមនេះ ÷
   ភាគល្អិតពីរអាចមានអំពើជាមួយគ្នាលុះត្រាតែភាគល្អិតទាំងពីរនោះ ...... ហើយ ...... មាន ... គ្រប់គ្រាន់ ។
2. ដូចម្តេចដែលហៅថា ÷
   ក. ទង្គិចប្រសិទ្ធ
   ខ. ទង្គិចមិនប្រសិទ្ធ
3. ចូរពន្យល់ថាហេតុអ្វីបានជាប្រតិកម្មរវាងម៉ាញេស្យូម និងអាស៊ីតប្រព្រឹត្តទៅកាន់តែលឿនកាលណា ÷
   ក. សីតុណ្ហភាពកើន
   ខ. ម៉ាញេស្យូមស្ថិតក្នុងភាពជាម្សៅ ។
4. ហេតុអ្វីបានជាកាតាលីករអាចពន្លឿនប្រតិកម្មគីមីបានទោះបីជានៅសីតុណ្ហភាពទាប ? ចូរពន្យល់ថា។

# ៥ ការសិក្សាបន្ថែមពីកាតាលីករ



បំពង់កែវនេះមានផ្ទុកល្បាយឧស្ម័នអុកស៊ីសែន និងអ៊ីដ្រូសែន។ ទោះបីជាគេទុកល្បាយឧស្ម័នទាំងពីរនេះយូរយ៉ាងណាក៏ដោយ ក៏គ្មានប្រតិកម្ម ជាមួយគ្នាដែរ។



ប្រសិនបើគេដាក់សរសៃប្លាទីននៅលើមាត់ បំពង់កែវល្បាយឧស្ម័ននេះនឹងផ្ទុះភ្លាម ដោយ បញ្ចេញសំឡេងប៉ុប ហើយបង្កើតបានជាទឹក។

ដូចនេះប្លាទីនគឺជាកាតាលីករចំពោះប្រតិកម្មរវាងអ៊ីដ្រូសែន និងអុកស៊ីសែន។ វាបង្កើនល្បឿនប្រតិកម្មហើយរក្សាលក្ខណៈ គីមីនៅដដែល។ ដ្យាក្រាមខាងក្រោមនេះបង្ហាញពីដំណើរការរបស់កាតាលីករ។




① ខ្សែកោងនេះបង្ហាញពីប្រតិកម្មនៅក្នុងបំពង់កែវទីមួយ។ ប្រតិកម្មនេះមិនអាចកើតឡើងបានទេលុះត្រាតែម៉ូលេគុល ដែលចូលរួមប្រតិកម្មប៉ះគ្នាដោយមានថាមពលគ្រប់គ្រាន់ដើម្បីផ្តាច់សម្ព័ន្ធ។

ថាមពលដែលត្រូវការចាំបាច់ដើម្បីឱ្យមាន ទង្គិចប្រសិទ្ធហៅថា **ថាមពលសកម្មកម្ម**។ នៅក្នុងបំពង់កែវទីមួយ អង្គធាតុប្រតិករទាំងពីរគ្មានថាមពល គ្រប់គ្រាន់ ដូចនេះប្រតិកម្មនេះមិនអាចកើតឡើងទេ។

② កាលណាមានវត្តមានប្លាទីន នោះថាមពលសកម្មកម្មថយចុះ។ ដូចនេះនាំឱ្យកើតមានទង្គិចប្រសិទ្ធមួយចំនួនហើយ ប្រតិកម្មក៏ចាប់ផ្តើមកើតមានឡើង។ វាជាប្រតិកម្មបញ្ចេញកំដៅ មានន័យថាវាផ្តល់ថាមពល។ ការបញ្ចេញកម្តៅ នេះធ្វើ ឱ្យទង្គិចប្រសិទ្ធកាន់តែកើតមានច្រើន ភ្លាមនោះប្រតិកម្មប្រព្រឹត្តទៅលឿន ដោយមានបន្ទុះទៀតផង ។

*កាតាលីករបន្ថយថាមពលដែលត្រូវការចាំបាច់សម្រាប់ឱ្យប្រតិកម្មប្រព្រឹត្តទៅបាន ឬម្យ៉ាងទៀតយើងអាចនិយាយបានថា កាតាលីករបន្ថយថាមពលសកម្មកម្ម។*

## ៥.១ ការពិនិត្យមើលឱ្យច្បាស់នៅលើកាតាលីករ

ក្នុងប្រតិកម្មខាងលើនេះ ប្លាទីនដើរតួជាកាតាលីករផ្ទៃប៉ះ។




ឧស្ម័នទាំងពីរនេះមិនទង្គិចគ្នាទេ តែ ម៉ូលេគុលរបស់វា ស្រូបដោយផ្ទៃលោហៈ។ ឧស្ម័នទាំងពីរ នេះនឹងស្ថិតនៅ ជិតគ្នាដែលអាចសម្រួលឱ្យប្រតិកម្មប្រព្រឹត្តទៅបាន។




កាលណាផ្ទៃប៉ះរបស់ប្លាទីនកាន់តែធំ នោះថាមពលដំណើរការ កាន់តែល្អ ព្រោះវាអាចស្រូបឧស្ម័នបានច្រើន។ កាតាលីករ ផ្សេងទៀតក៏មានដំណើរការដូចគ្នានេះដែរ។

*ឧទាហរណ៍*   នៅក្នុងបំពង់បំលែងឧស្ម័នដែលស្ថិត នៅក្នុងបំពង់សឺមាំងរថយន្តឧស្ម័នពុល ត្រូវបានស្រូបដោយលោហៈ រ៉ូដ្យូម ។ នៅទីនោះ ឧស្ម័នទាំងនេះមានអំពើ ជាមួយអុកស៊ីសែនដើម្បីបង្កើតបានឧស្ម័នដែលមានលក្ខណៈពុលតិច ។

## ៥.២ កាតាលីករនៅក្នុងឧស្សាហកម្ម

ប្រតិកម្មគីមីជាច្រើនក្នុងឧស្សាហកម្ម ជាប្រតិកម្មស្រូបកំដៅ ដូចនេះដើម្បីឱ្យប្រតិកម្មកើតមានឡើងគេត្រូវតែផ្តល់ថាមពលឱ្យវា។ ថាមពលដែលត្រូវផ្តល់អាចបានមកពីឧស្ម័ន ប្រេង ធ្យូងថ្ម ឬអគ្គិសនី។ ប៉ុន្តែទោះបីជាថាមពលទាំងនោះបានមកពីប្រភពណាក៏ដោយ ក៏គេត្រូវចំណាយសោហ៊ុយយ៉ាងច្រើន ហើយជាបញ្ហាមួយដ៏ធំដែលឧស្សាហកម្មទាំងឡាយកំពុងប្រឈមមុខ។

កាលណាគេប្រើកាតាលីករ ប្រតិកម្មប្រព្រឹត្តទៅលឿន *នៅសីតុណ្ហភាពណាមួយ* មានន័យថាគេឆាប់ទទួលបានផលិតផល ដោយចំណាយពេលវេលាតិច និងសន្សំថវិកាផងដែរ។ មិនតែប៉ុណ្ណោះ ប្រតិកម្មក៏អាចប្រព្រឹត្តទៅលឿនទោះបីជានៅសីតុណ្ហភាពទាបក៏ដោយ ដោយគេប្រើប្រាស់ថាមពលតិច និងអាចរកប្រាក់ចំណេញបានច្រើន ។

*សំគាល់*   កាតាលីករមានទម្រង់ និងទំហំខុសៗគ្នា។ វាអាចមានរាងមូល សំប៉ែត ទ្រវែង ប្រហោងក្នុង ...។

ដូច្នេះកាតាលីករអាចជួយសម្រួលលំនាំប្រតិកម្មមួយដែលចំណាយថវិកាអស់ច្រើនទៅជាចំណាយថវិកាអស់តិច។ បញ្ហានេះវាធ្វើឱ្យកាតាលីករមានតួនាទីសំខាន់ណាស់នៅក្នុងឧស្សាហកម្ម រហូតដល់គេផលិតកាតាលីករដល់ជាង ១០ លានតោនក្នុងមួយឆ្នាំ។ កាតាលីករផ្សេងៗគ្នា ប្រើសម្រាប់ប្រតិកម្មផ្សេងគ្នា ដូចជា ÷

- **វ៉ាណាដ្យូមពែអុកស៊ីត** ត្រូវបានគេប្រើនៅក្នុងប្រតិកម្មបំលែងពីស្ពាន់ធ័រឌីអុកស៊ីតទៅជាស្ពាន់ធ័រទ្រីអុកស៊ីតក្នុងការផលិតអាស៊ីតស៊ុលផួរិច ។
- **ដែក** ជាកាតាលីករនៅក្នុងប្រតិកម្មរវាងអាសូត និងអ៊ីដ្រូសែន ក្នុងការផលិតអាម៉ូញាក់ ។
- **ZSM-5** ជាកាតាលីករសំរាប់ប្រតិកម្មបំលែងពីអេតាណុលទៅជាអ៊ីដ្រូកាបួដើម្បីប្រើនៅក្នុងប្រេងឥន្ធនៈ។ សារធាតុនេះគឺជាសមាសធាតុរវាងស៊ីលីស្យូម អាលុយមីញ៉ូម និង អុកស៊ីសែន ។

នៅពេលប្រតិកម្មទោះជាកាតាលីករពុំមានបម្រែបម្រួលគីមីក៏ដោយ ក៏វាបានស្រូបនូវធាតុមិនសុទ្ធដែរ ដែលជាហេតុធ្វើឱ្យកាតាលីករអស់សកម្មភាព ហេតុដូចនេះហើយបានជាគេតែងតែញផ្លាស់ប្តូរកាតាលីករនៅក្នុងរោងចក្រគីមី។

### សំណួរ

1. ចូរពន្យល់ពីដំណើរការរបស់កាតាលីករផ្ទៃប៉ះ ។
2. ហេតុអ្វីបានជាកាតាលីករអាចជួយសម្រួលលំនាំប្រតិកម្មមួយដែលចំណាយអស់ថវិកាច្រើនទៅជាចំណាយថវិកាអស់តិច? ចូរលើកហេតុផលពីរយ៉ាងមកបញ្ជាក់។
3. ហេតុអ្វីបានជាកាតាលីករតែមួយមិនដំណើរការសម្រាប់គ្រប់ប្រតិកម្មទាំងអស់? ចូរលើកហេតុផលមកបញ្ជាក់។

# ៦ អង់ស៊ីម

## ៦.១ ដូចម្តេចដែលហៅថាអង់ស៊ីម?

**អង់ស៊ីម** គឺជាប្រូតេអ៊ីនដែលដើរតួជា **កាតាលីករ**។ កាតាលីករនេះខុសប្លែកពីកាតាលីករដទៃទៀតដោយសារតែវា*កើតឡើងពីកោសិកាមានជីវិត* ។

គ្រប់កោសិកាមានជីវិតទាំងអស់ក្នុងរុក្ខជាតិ និងសត្វ រួមទាំងខ្លួនមនុស្សផងដែរ ប្រៀបដូចជារោងចក្រគីមីមួយដែលមានដំណើរប្រតិកម្មជាប់រហូត។ ឧទាហរណ៍ ប្រតិកម្មក្នុងសារពាង្គកាយអាចជួយឱ្យយើងធ្វើចលនាបានមើលឃើញ និងរំលាយអាហារ ...។ ប៉ុន្តែសីតុណ្ហភាពក្នុងខ្លួនរបស់យើងទាបណាស់ ដើម្បីឱ្យប្រតិកម្មទាំងនេះប្រព្រឹត្តទៅលឿនគ្រប់គ្រាន់ និងដើម្បីឱ្យយើងរស់រានមានជីវិត កោសិកាទាំងឡាយត្រូវប្រើប្រាស់អង់ស៊ីមជាកាតាលីករ។ អង់ស៊ីមអាចធ្វើឱ្យប្រតិកម្មមួយប្រព្រឹត្តទៅរហូតដល់មួយលានដងលឿនជាងប្រតិកម្មគ្មានអង់ស៊ីម។



អង់ស៊ីមមានម៉ូលេគុល ធំហើយសាំញ៉ាំ។ នេះជា គំរូនៃម៉ូលេគុលអង់ស៊ីមមួយ

គេចែកអង់ស៊ីមទៅតាមក្រុមអាស្រ័យលើមុខងាររបស់វា។

- **អាមីឡាស** បំបែកអាមីដុង។ កោសិកាទាំងឡាយនៅក្នុងមាត់របស់យើងផលិតអាមីឡាស រួចបញ្ចេញទៅក្នុងទឹកមាត់។ វាជាកាតាលីករក្នុងប្រតិកម្មបំបែកអាមីដុងក្នុងម្ហូបអាហារដែលយើងទំពារ។
- **ប្រូតេអាស** បំបែកប្រូតេអ៊ីន ក្នុងពេលរំលាយអាហារ ។
- **លីប៉ាស** បំបែកខ្លាញ់ និងប្រេង (លីពីត) ។

## ៦.២ ការសិក្សាអង់ស៊ីមក្នុងទីពិសោធ




អ៊ីដ្រូសែនពែអុកស៊ីតជាអង្គធាតុរាវគ្មានពណ៌ហើយវារងប្រតិកម្មបំបែកដូចខាងក្រោម ÷

អ៊ីដ្រូសែនពែអុកស៊ីត ⟶ ទឹក + អុកស៊ីសែន

$$H_2O_2\,(l) \longrightarrow H_2O(l) + O_2\,(g)$$

យើងអាចប្រើរងើកភ្លើងដើម្បីធ្វើតេស្តអុកស៊ីសែនដែលកកើត។ គេចាក់អ៊ីដ្រូសែនពែអុកស៊ីតទៅក្នុងស៊ីឡាំងក្រិតចំនួនបួន ហើយគេទុកស៊ីឡាំងក្រិតមួយជាសូលុយស្យុងស្តង់ដាសម្រាប់ត្រួតពិនិត្យ។ បន្ទាប់មកគេដាក់ម៉ង់កាណែស IV អុកស៊ីត ថ្លើមឆៅ និង ថ្លើមឆ្អិនទៅក្នុងស៊ីឡាំងក្រិតដទៃទៀត ។










អ៊ីដ្រូសែនពែអុកស៊ីតបំបែកដោយខ្លួនឯងយ៉ាងយឺតៗឱ្យជាទឹក និងអុកស៊ីសែន ។

ម៉ង់កាណែស IV អុកស៊ីតអាចធ្វើឱ្យប្រតិកម្មនេះលឿនជាងរាប់ពាន់ដង ។

ថ្លើមឆៅក៏អាចពន្លឿនប្រតិកម្មនេះដែរ អង្គធាតុរាវនេះនឹងផុលឡើងនៅពេលអុកស៊ីសែនបែកពពុះ ។




ដូចនេះប្រាកដជាមានអ្វីមួយនៅក្នុងថ្លើមឆៅដើរតួជាកាតាលីករសម្រាប់ប្រតិកម្មបំបែកនេះ ។ វាជាអង់ស៊ីម **កាតាឡាស** ដែលបង្កើតឡើងដោយកោសិកាថ្លើម ។ កាតាឡាសមានសារៈសំខាន់ណាស់សម្រាប់ខ្លួនយើង វាអាចធ្វើឱ្យយើងជៀសផុតពីជាតិពុល ។ ប្រតិកម្មជាច្រើននៅក្នុងកោសិការបស់យើងផលិតអ៊ីដ្រូសែនពែអុកស៊ីត ដែលជាសារធាតុពុល ។ ប៉ុន្តែកោសិកាខ្លួនយើងផ្សេងទៀតក៏ផលិតកាតាឡាសដែរ ។ មួយម៉ូលេគុលកាតាឡាសអាចធ្វើកាតាលីកម្ម បំបែកម៉ូលេគុលអ៊ីដ្រូសែនពែអុកស៊ីត ៥លានក្នុងរយៈពេលតែមួយនាទី ។

## ៦.៣ ដំណើរការរបស់អង់ស៊ីម

គំរូសាមញ្ញខាងនេះបង្ហាញពីដំណើរការរបស់អង់ស៊ីមនៅពេលវាធ្វើកាតាលីកម្មក្នុងប្រតិកម្មបំបែកម៉ូលេគុលមួយ (ដូចជា អ៊ីដ្រូសែនពែអុកស៊ីត) ។










ដំបូងវាត្រូវតែផ្គុំគ្នាដូចជាល្បែងតម្រៀបរូបដែរ ។ ចំពោះករណីនេះ ម៉ូលេគុលអង្គធាតុប្រតិករត្រូវតែមានទម្រង់ត្រូវគ្នានឹងអង់ស៊ីម ។

ប្រព័ន្ធសាំញ៉ាំដែលបានបង្កើតឡើងអាចសម្រួលដល់ម៉ូលេគុលអង្គធាតុប្រតិករក្នុងការបំបែក ។ នៅពេលដែលការបំបែកចប់សព្វគ្រប់ ....

... ម៉ូលេគុលផលិតផលបែកចេញពីគ្នា ។ ម៉ូលេគុលមួយទៀតរបស់អង្គធាតុប្រតិករដែលមានទម្រង់ត្រូវគ្នានឹងអង់ស៊ីមនឹងចូលមកជំនួសបន្តដើម្បីបំបែកតទៅទៀត ។

*សំគាល់*

- អង់ស៊ីមដំណើរការល្អនៅក្នុងលក្ខខ័ណ្ឌដែលកោសិកាមានជីវិតបង្កើតវា ។
- អង់ស៊ីមភាគច្រើនមានដំណើរការល្អនៅសីតុណ្ហភាពចន្លោះពី 25-45 $^oC$ ពីព្រោះកោសិកាមានជីវិតភាគច្រើនអាចរស់ នៅបានក្នុងចន្លោះសីតុណ្ហភាពនេះ ។ ( សីតុណ្ហភាពក្នុងខ្លួនមនុស្សគឺ 37 $^oC$ ) ។
- នៅសីតុណ្ហភាពខ្ពស់ អង់ស៊ីមប្រែប្រួលទម្រង់របស់វា ដែលជាហេតុធ្វើឱ្យវាមិនអាចដំណើរការបាន មានន័យថា វាប្តូរ **លក្ខណះរបស់វា** ។ ប៉ុន្តែនៅសីតុណ្ហភាពទាប វានឹងលែងមានសកម្មភាព ។
- ក្រាបខាងក្រោមនេះបង្ហាញពីល្បឿនកាតាលីកម្មរបស់ប្រតិកម្មអាស្រ័យសីតុណ្ហភាព ។ អង់ស៊ីមមានសកម្មភាពខ្លាំង បំផុតនៅសីតុណ្ហភាព 40 $^oC$ ដែលជាសីតុណ្ហភាព **អតិបរមា** របស់វា ។
- អង់ស៊ីមក៏មានសកម្មភាពល្អផងដែរ ក្នុងចន្លោះតម្លៃ pH ណាមួយ វាអាស្រ័យទៅលើកោសិកាដែលបង្កើតវា ។ យើង អាចធ្វើឱ្យអង់ស៊ីមប្តូរលក្ខណះរបស់វាដោយបន្ថែមអាស៊ីត ឬបាស ។




## ៦.៤ អង់ស៊ីមក្នុងអាហារ

ដូចដែលយើងបានដឹងរួចមកហើយថា អង់ស៊ីមកើតចេញពីកោសិការបស់រុក្ខជាតិ និងសត្វ ហើយអង់ស៊ីមនីមួយៗ មានមុខងារជាក់លាក់របស់វា ។ ឧទាហរណ៍ អង់ស៊ីមមួយចំនួនអាចធ្វើឱ្យផ្លែឈើ បន្លែ និងសាច់រលួយ ។ សកម្មភាពរបស់ អង់ស៊ីមនៅតែបន្តរហូតបន្ទាប់ពីគេបេះ និងសម្លាប់វា ។ រួមជាមួយបាក់តេរី និងអតិសុខុមប្រាណ វាអាចធ្វើឱ្យម្ហូបអាហារ រលួយ ។

- ការរក្សាម្ហូបអាហារក្នុងទូទឹកកកអាចធ្វើឱ្យមិនងាយរលួយ ។
- អង់ស៊ីមស្ទើរតែគ្មានសកម្មភាពទាល់តែសោះ នៅសីតុណ្ហភាពប្រហែល – 18 $^oC$ ប៉ុន្តែវាមិនបាត់បង់ទម្រង់ និង លក្ខណះទេ ហើយនៅសីតុណ្ហភាព 0 $^oC$ វាមានសកម្មភាពតិចតួច ហេតុដូចនេះហើយបានជាបន្លែនៅត្រូវបាន គេស្រុស មុននឹងដាក់វាទៅក្នុងទូទឹកកក ។

**សំណួរ**

1. ដូចម្តេចដែលហៅថាអង់ស៊ីម ?

2. តើអាមីឡាសមានតួនាទីដូចម្តេចនៅក្នុងរាងកាយយើង ?

3. តើឧស្ម័នអ្វីកើតមានឡើងនៅពេលអ៊ីដ្រូសែនពែអុកស៊ីតបំបែក? តើគេអាចធ្វើតេស្តឧស្ម័ននោះយ៉ាងដូចម្តេច?

4. តើអង់ស៊ីមដែលមាននៅក្នុងថ្លើមឈ្មោះអ្វី?

5. ចូរពន្យល់ពីដំណើរការប្រព្រឹត្តទៅរបស់អង់ស៊ីម?

6. តើពាក្យថា "ប្រែប្រួលទម្រង់" មានន័យដូចម្តេច? តើអង់ស៊ីមប្រែប្រួលទម្រង់យ៉ាងដូចម្តេច?

7. ហេតុអ្វីបានជាថ្លើមឆ្អិនមិនអាចធ្វើកាតាលីកម្មទៅលើអ៊ីដ្រូសែនពែអុកស៊ីតបាន?

8. តើអង់ស៊ីមនឹងប្រែទៅជាយ៉ាងណានៅសីតុណ្ហភាពក្រោម -18 $^oC$ ?

# ៧ បម្រើប្រាស់អង់ស៊ីមតាមបែបបុរាណ

## ៧.១ ការត្រឡប់នៅមើលសម័យដើម

យើងបានប្រើប្រាស់អង់ស៊ីមរាប់ពាន់ឆ្នាំមកហើយដោយមិនដឹងខ្លួនក្នុងការផលិតស្រា ស្រាបៀរ និងនំប៉ុង។ ដំណើរការទាំងបីនេះពឹងផ្អែកលើ **មេដំបែ** ដែលជាផ្សិតផ្សំឡើងដោយកោសិកាមានជីវិតរាប់លាន។ តាមពិតពាក្យថាអង់ស៊ីមកើតមកពីពាក្យក្រិចដែលមានន័យថា "នៅក្នុងមេដំបែ" *" in yeast"* ។

នៅឆ្នាំ 1926 គីមីជីវវិទូរបស់ជនជាតិអាមេរិកាំងឈ្មោះ ចេម សាំណើ (James Sumner) បានធ្វើយោបកក្រាមអង់ស៊ីមឈ្មោះ Urease ពីសណ្តែក។ របកគំហើញនេះបណ្តាលឱ្យកើតជាសំណួរសួរថា តើគេអាចធ្វើយោបកអង់ស៊ីម ហើយប្រើវា ជាកាតាលីករនៅក្នុងរោងចក្របានដែរឬទេ ?

បច្ចុប្បន្ននេះគេប្រើអង់ស៊ីមយ៉ាងទូលំទូលាយនៅក្នុងឧស្សាហកម្ម។ ពេលខ្លះវត្តមាននៃកោសិកាមានជីវិតជាផ្នែកមួយនៃដំណើរការ (ឧទាហរណ៍ដូចជា មេដំបែ ក្នុងការផលិតនំប៉ុង)។

ជាបន្តទៀត យើងនឹងពិនិត្យមើលនូវការប្រើប្រាស់អង់ស៊ីមតាមបែបបុរាណមួយចំនួន។

## ៧.២ ដំបែ និងល្បឿង

ដំបែជាផ្សិតដែលផ្សំដោយកោសិកាមានជីវិតតូចៗរាប់សិបលាន។ វារស់ដោយសារស្ករ ដោយប្រើអង់ស៊ីមដើម្បីបំបែក ស្ករឱ្យទៅជាអេតាណុល និងឧស្ម័នកាបូនិច។ លំនាំនេះគេឱ្យឈ្មោះថា **ល្បឿង**។ យើងអាចបង្ហាញលំនាំនេះនៅក្នុងទីពិសោធ។



ទឹកកំបោរថ្លាប្រែល្អក់ដូចជាទឹកដោះគោ ដែលបញ្ជាក់ថា កាបូនឌីអុកស៊ីតបានកើតឡើង។ ដោយសារតែអេតាណុល ជាអង្គធាតុរាវ ដូចនេះវានៅស្ថិតនៅក្នុងកែវដដែល ។សមីការតាងល្បឿងនេះគឺ ÷

គ្លុយកូស $\xrightarrow{\text{អង់ស៊ីមក្នុងដំបែ}}$ អេតាណុល + កាបូនឌីអុកស៊ីត

$$C_6H_{12}O_6\,(aq) \longrightarrow 2\,C_2H_5OH\,(l) + 2\,CO_2\,(g)$$

ផលិតផលទាំងពីរខាងលើនេះជាមូលដ្ឋាននៃឧស្សាហកម្ម។

## ៧.៣ ធ្វើនំប៉័ងដោយប្រើកាបូនឌីអុកស៊ីតដែលបានពីល្បឿង

ម្សៅនំប៉័ងផ្ទុកទៅដោយស្ករ និងដំបែ។ ពេលគេទុកម្សៅនំប៉័ងនេះនៅកន្លែងក្តៅអស់រយៈពេលប្រហែលមួយម៉ោង មក ដំបែក៏បំបែកស្ករ ហើយបង្កើតកាបូនឌីអុកស៊ីត។ លំនាំនេះធ្វើឱ្យម្សៅនំប៉័ងឡើង។ បន្ទាប់មកគេដុតវានៅក្នុងឡ កម្តៅ។ កម្តៅធ្វើឱ្យកាបូនឌីអុកស៊ីតរីកមាឌ ហើយម្សៅកាន់តែរីកធំ។ កម្តៅនេះក៏ធ្វើឱ្យដំបែងាប់ផងដែរ។

## ៧.៤ ធ្វើស្រា និងស្រាបៀរ ដោយប្រើអេតាណុលដែលបានពីល្បឿង

អេតាណុលជាអាល់កុលមាននៅក្នុងភេសជ្ជៈស្រវឹង ហើយក៏ជាធាតុបង្កដែលធ្វើឱ្យមនុស្សយើងស្រវឹងផងដែរ។

**ស្រាបៀរ** ផលិតពីគ្រាប់ធញ្ញជាតិម្សៅង (barley) និងដំបែ តាមលំនាំល្បឿង។ ដំបូងគេត្រូវយកគ្រាប់ធញ្ញជាតិនេះ ទៅជ្រលក់ឱ្យសើមជាមួយនឹងទឹកក្តៅ បន្ទាប់មកគេកិនវាឱ្យទៅជាម្សៅរាវហៅថា ម្សៅវ៉ត (wort)។ ល្បាយនេះផ្ទុកទៅ ដោយស្ករ ដែលបានមកពីការបំបែកអាមីដុងនៅក្នុងគ្រាប់ធញ្ញជាតិ។ គេបន្ថែមដំបែទៅក្នុងម្សៅវ៉ត ហើយលំនាំល្បឿង ក៏កើតឡើង ដោយបង្កើតបានអាល់កុលរាវ។ នៅពេលបរិមាណអាល់កុលឈានដល់កម្រិតមួយដែលគេចង់បានគេត្រូវ ញែកយកដំបែចេញ។

**ស្រា** ដំបូងត្រូវបុកផ្លែទំពាំងបាយជូដើម្បីគាបយកទឹក បន្ទាប់មកថែមដំបែ ហើយលំនាំល្បឿងក៏ចាប់ផ្តើម។ លំនាំ ល្បឿងនេះបន្តរហូតដល់គេយកដំបែចេញ ឬអាល់កុលបានបំពុលដំបែនេះ។



## ៧.៥ ធ្វើយ៉ាអួ (Yoghurt)

ការធ្វើ Yoghurt ក៏ដូចជាការធ្វើនំប៉័ងដែរ គឺត្រូវមានវត្តមាននៃកោសិកាមានជីវិត។ ការធ្វើ Yoghurt នេះដំបូងគេ ត្រូវយកទឹកដោះគោទៅសម្លាប់បាក់តេរីដោយដុតកម្តៅ បន្ទាប់មកគេបន្ថែមបាក់តេរីពិសេសដែលអាចឱ្យលំនាំនេះចាប់ ផ្តើមបាន។ បាក់តេរីនេះផលិតនូវអង់ស៊ីមដែលអាចបំលែងស្ករ (ឡាក់តូស) នៅក្នុងទឹកដោះគោ ឱ្យទៅជាអាស៊ីត ឡាក់ទិច និង សារធាតុដទៃទៀត និង ធ្វើឱ្យប្រូតេអ៊ីនឡើងក្រាស់។

## ៧.៦ ធ្វើប្រូម៉ា (Cheese)

គេក៏ធ្វើ Cheese ពីទឹកដោះគោផងដែរ ដោយប្រើអង់ស៊ីម ប៉ុន្តែម្តងនេះកោសិកាដែលផលិតអង់ស៊ីមពុំមានវត្តមានទេ ។ កាលពីអតីតកាលគេផលិត cheese ដោយប្រើ rennet ដែលជាសារធាតុមួយយើងអាចទទួលបានពីពោះគោទី៤របស់សត្វគោ។ ពោះគោនេះរួមមានអង់ស៊ីម **ស៊ីម៉ូស៊ីន និងប៉ិបស៊ីន**។ ដើម្បីធ្វើ Cheese នេះ កសិករត្រូវកាប់គោហើយយកពោះទី៤ របស់វាមកហាលឱ្យស្ងួត។ នៅពេលដែលគេត្រូវធ្វើ Cheese គេត្រូវច្រៀកក្រពះនោះជាបន្ទះហើយដាក់ទៅក្នុងទឹកដោះគោ។

បច្ចុប្បន្ននេះ វាមានការលំបាកណាស់ក្នុងការរកពោះគោឱ្យបានគ្រប់គ្រាន់។ ដូចនេះដើម្បីចំណាយថវិកាអស់តិចគេបានផលិតអង់ស៊ីមដោយប្រើបាក់តេរីរស់នៅក្នុងធុង។ បាក់តេរីនេះមានសែនដែលអាចបំពេញភារកិច្ចនេះបាន។ អង់ស៊ីម (សំខាន់គឺស៊ីម៉ូស៊ីន) ត្រូវគេបន្ថែមទៅក្នុងទឹកដោះគោដែលគេសម្លាប់បាក់តេរីរួច បន្ទាប់មកក៏កើតជាអង្គធាតុរឹងដូចកៅស៊ូហៅថា Curd ហើយនិងអង្គធាតុរាវហៅថា Whey។ បន្ទាប់មកគេបង្ហូរអង្គធាតុរាវនេះចេញ។ ប្រព្រឹត្តកម្មបន្ថែមទៀតធ្វើឱ្យ Curd នេះក្លាយទៅជា Cheese ។

**សំណួរ**

1. ដូចម្តេចដែលហៅថា ដំបែ?
2. ចូរប្រាប់ឈ្មោះលំនាំដែលក្នុងនោះដំបែបំបែកស្ករ រួចសរសេរសមីការតាងប្រតិកម្មជាអក្សរ។
3. តើគេធ្វើអត្តសញ្ញាណកម្មកាបូនឌីអុកស៊ីតដូចម្តេច ?
4. ចូរពន្យល់ពីការប្រើអង់ស៊ីមក្នុង ÷
   ក. ការដុតនំប៉័ង
   ខ. ការផលិតស្រា ។
5. ក. ចូរប្រាប់ឈ្មោះអង់ស៊ីមសំខាន់នៅក្នុងការផលិត Cheese ។
   ខ. ពីអតីតកាល តើគេទទួលបានអង់ស៊ីមនេះពីណាមកកាល? តើបច្ចុប្បន្ននេះគេបានវាមកពីណា ?

# ៨ ការប្រើប្រាស់អង់ស៊ីមក្នុងពេលបច្ចុប្បន្ន

បច្ចុប្បន្ននេះ គេបានប្រើអង់ស៊ីមរាប់រយប្រភេទផ្សេងៗគ្នា។

*ឧទាហរណ៍*

- នៅក្នុង **សារធាតុជម្រះជីវៈ** ÷ ស្នាមប្រឡាក់ដូចជាញើស ជ័រស្មៅ និងឈាមមានផ្ទុកប្រូតេអ៊ីន អាមីដុង និងអង្គធាតុ ខ្លាញ់។ ដូចនេះដើម្បីជម្រះស្នាមប្រឡាក់ទាំងនោះ គេបានបញ្ចូលអង់ស៊ីម ប្រូតេអាស អាមីឡាស និងលីប៉ាស ទៅក្នុងសារធាតុជម្រះ ហើយស្នាមប្រឡាក់ទាំងនោះនឹងជ្រះនៅពេលបោកគក់ ។

- នៅក្នុងម្ហូបអាហារកូនក្មេង ៖ ប្រូតេអាសជួយរំលាយប្រូតេអ៊ីននៅក្នុងម្ហូបអាហារជាមុនដើម្បីសម្រួលការរំលាយអាហាររបស់កុមារ ។
- នៅក្នុងសូកូឡា ដែលមានស្នូលទន់ ៖ ស្នូលនោះផ្ទុកទៅដោយស្ករអំពៅ (សាកា្ររ៉ូស) និងអង់ស៊ីមអាំងវែតាស (invertase)បន្តិចបន្តួច ។ គេស្រោបវាដោយសូកូឡាហើយទុកចោលពីរសប្តាហ៍ ពេលនោះ អង់ស៊ីមបានបំបែកសាកា្ររ៉ូស ទៅជាស្ករធម្មតា ហើយឱ្យស្នូលនោះទៅជារាវ ។
- គេប្រើអង់ស៊ីមកាបូអ៊ីដ្រាសដើម្បីបំប្លែងម្សៅអាមីដុងរាវ (ឧទាហរណ៍ម្សៅដំឡូងបារាំង ដែលមិនទាន់ផ្អែម) ឱ្យទៅ ជាស៊ីរ៉ូផ្អែម សម្រាប់ធ្វើនំ ភេសជ្ជៈ និងស្ករគ្រាប់ ។គេប្រើអង់ស៊ីមអ៊ីសូមែរ៉ាស ដើម្បីបំប្លែងគ្លុយកូស (ស្ករធម្មតា) ទៅជាព្រុចតូស (ស្ករមួយប្រភេទទៀត) ដែលមានរសជាតិផ្អែមជាងមុន ។ ហេតុនេះហើយគេត្រូវ ការស្ករព្រុចតូសតិចសម្រាប់ប្រើនៅក្នុងម្ហូបអាហាររក្សារាង ។
- គេប្រើអង់ស៊ីមសែលុយឡាសនៅក្នុងការបោកគក់ខោខូវប៊ូយពណ៌ខៀវឱ្យព្រលែតពណ៌ ។ គេដាក់ខោខូវប៊ូយនៅក្នុងម៉ាស៊ីនបោកគក់ជាមួយថ្មខាត់ ដើម្បីជម្រះជាតិពណ៌ខ្លះចេញពីសាច់ខោនោះ ។

## ៨.១ សារៈប្រយោជន៍អង់ស៊ីម

នៅក្នុងឧស្សាហកម្មគេប្រើអង់ស៊ីមយ៉ាងទូលំទូលាយជាកាតាលីករព្រោះ ៖

- វាមានដំណើរការល្អនៅសីតុណ្ហភាពទាប ដែលអាចធ្វើឱ្យគេសន្សំសំចៃថវិកា ។
- វាមានដំណើរការនៅល័ក្ខខ័ណ្ឌសមស្រប (នៅក្នុងទឹក ហើយជាធម្មតា ក្នុងតម្លៃ pH ប្រហែល៧ ) ដែលមិនធ្វើឱ្យប៉ះពាល់ដល់សម្លៀកបំពាក់ ឬម្ហូបអាហារ ។
- គេអាចគ្រប់គ្រងវាយ៉ាងងាយ ហើយអាចបញ្ឈប់ដំណើរការរបស់វាដោយផ្លាស់ប្តូរសីតុណ្ហភាព ឬ តម្លៃ pH ។
- វាអាចរលួយ ហើយកាកសំណល់របស់វាមិនប៉ះពាល់ដល់បរិស្ថានទេ ។

## ៨.២ ការផលិតអង់ស៊ីម

បច្ចុប្បន្ននេះអង់ស៊ីមភាគច្រើនដែលគេប្រើនៅក្នុងឧស្សាហកម្មបានមកពីបាក់តេរីដែលរស់អាងឬក្នុងទឹកស៊ុបដែលផ្ទុកទៅដោយសារធាតុចិញ្ចឹមដែលអង់ស៊ីមទាំងនោះត្រូវការ ។ នៅពេលបរិមាណអង់ស៊ីមដែលត្រូវការបានផលិតរួចហើយ គេត្រូវញែកវាចេញពីទឹកស៊ុប ។ អង់ស៊ីមដែលទទួលបានជាអង្គធាតុរឹង ហើយបានគេវាទៅលក់ទៅឱ្យរោងចក្រ ។

បាក់តេរីមួយអាចផលិតអង់ស៊ីមរហូតដល់ជាង 1000 ប្រភេទ ហេតុដូចនេះហើយបានជាបាក់តេរីត្រូវបានគេបង្កាត់សែនដើម្បីផលិតអង់ស៊ីមដែលគេត្រូវការ ។

បច្ចុប្បន្ននេះ អ្នកវិទ្យាសាស្ត្រកំពុងតែស្វែងរកបាក់តេរី **extremophile** (បាក់តេរីដែលរស់នៅក្នុងកន្លែងត្រជាក់ ឬក្តៅខ្លាំង) យ៉ាងហ្មត់ចត់ ។ អង់ស៊ីមដែលបង្កើតដោយបាក់តេរីនេះនឹងអាចមានដំណើរការនៅក្នុងលក្ខខណ្ឌមួយពិបាក១ ។

សែននៅក្នុងបាក់តេរីនេះអាចប្រើដើម្បីបង្កាត់ជាមួយបាក់តេរីធម្មតាឱ្យបានជាអង់ស៊ីមដែលធន់ជាង ឧទាហរណ៍អង់ស៊ីមដែលគេប្រើនៅក្នុងទឹកពុះ ឬនៅតម្លៃ pHទាប។ មានន័យថានៅថ្ងៃណាមួយនឹងមានអង់ស៊ីមប្រភេទនេះប្រើប្រាស់នៅគ្រប់ឧស្សាហកម្ម។

## ៨.៣ បម្រើបម្រាស់អង់ស៊ីម







ដើម្បីបោកខោខូវប៊យខៀវឱ្យមានពណ៌ព្រលែត យើងត្រូវដាក់ខោទាំងនោះ ទៅក្នុងម៉ាស៊ីនបោកគក់ធំមួយជាមួយនឹងអង់ស៊ីមសែលុយឡាស និងថ្មខាត់បន្តិច រួចចុចកុងតាក់បើក។ នៅពេលដែលការបោកគក់ចប់សព្វគ្រប់ យើងបង្ហូរទឹកចេញ បើកគម្របម៉ាស៊ីន ហើយយកខោទៅហាល។ នេះជា ឧទាហរណ៍មួយនៃ**លំនាំរួម**។ យើងត្រូវដាក់សម្ភារៈ និងអង្គធាតុទាំងអស់រួមគ្នា រួចចាប់ផ្តើមដំណើរការ។ វាមានការចាប់ផ្តើម និងបញ្ចប់ជាក់លាក់។

សូលុយស្យុងwhey ជូរ(បានមកពីការផលិត cheese) ត្រូវបានបំប្លែងទៅជាសូលុយស្យុង ផ្អែមសម្រាប់ធ្វើបង្អែម ឬនំដោយប្រើអង់ស៊ីមឡាក់តាស។ ក្នុងលំនាំនេះ អង់ស៊ីមត្រូវ បានគេភ្ជាប់នៅក្នុងប្លាស្ទិច។ សូលុយស្យុង wheyជូរត្រូវបានគេចាក់តាមបំពង់ពីខាង លើ។ នៅពេលដែលវាឆ្លងកាត់គ្រាប់ប្លាស្ទិច នោះអង់ស៊ីម ចាប់ផ្តើមដំណើរការ។ សូលុយស្យុង wheyផ្អែមនឹងហូរ ចេញក្រៅតាមបំពង់ខាងក្រោម។ លំនាំនេះហៅថា **លំហូរ ឥតឈប់**។

ដំណើរការលំហូរមានសារៈសំខាន់ជាច្រើនដូចជា÷

- ដោយសារតែអង់ស៊ីមត្រូវបានគេបង្ខាំងទុកឱ្យនៅមួយកន្លែង ដូចនេះគេអាចប្រើវាបានរហូតដល់វាអស់សកម្មភាព ។ ធ្វើដូចនេះយើងអាចសន្សំសំចៃថវិកា (អង់ស៊ីមមានតម្លៃថ្លៃ) ប៉ុន្តែនៅក្នុងលំនាំរួម យើងមិនអាចប្រើអង់ស៊ីមនោះ បានម្តងទៀតទេ ព្រោះវាមានការលំបាកក្នុងការញែកអង់ស៊ីមពីអង្គធាតុរាវ ។
- ការប្រើលំនាំលំហូរឥតឈប់ យើងអាចគ្រប់គ្រងប្រតិកម្មបានរហ័សនិងងាយស្រួលដោយគ្រាន់តែតំរូវល្បឿនលំហូរ យើងមិនអាចគ្រប់គ្រងលំនាំរួមបានដោយងាយទេ។
- នៅក្នុងលំនាំលំហូរឥតឈប់ យើងមិនចាំបាច់ចុចកុងតាក់បើកបិទដូចលំនាំរួមទេ។ លំនាំនេះអាចមានដំណើរការរហូត ហើយវាអាចគ្រប់គ្រងដោយកុំព្យូទ័របានទៀតផង ដោយមានការធ្វើតេស្តផលិតផលដោយស្វ័យប្រវត្តិ

នៅពេលវាហូរចេញមក ដើម្បីឱ្យដឹងថាវាមានដំណើរការល្អ។ (ប្រសិនបើមានបញ្ហាកុំព្យូទ័រ នឹងបិទលំហូរភ្លាម)។

ប៉ុន្តែអង់ស៊ីមត្រូវតែមានស្ថិរភាពដើម្បីឱ្យលំនាំនេះប្រព្រឹត្តទៅបានល្អ។ ប្រសិនបើវាត្រូវបានបំផ្លាញដោយបម្រែបម្រួលតម្លៃ pH តិចតួច នោះយើងនឹងត្រូវរៀបចំប្តូរគ្រាប់ប្លាស្ទិច និងដំឡើងសារជាថ្មី។

## សំណួរ

1. គេថែមអង់ស៊ីមទៅក្នុងម្សៅសាប៊ូមួយចំនួន ÷

   ក. ចូរពន្យល់ និងប្រាប់ឈ្មោះអង់ស៊ីមទាំងនោះ ?

   ខ. ម្សៅសាប៊ូទាំងនេះមិនគួរយកទៅបោកគក់សំពត់សូត្រ ឬឡែនទេ។ ហេតុអ្វី ?

   គ. ហេតុអ្វីបានជាគេមិនគប្បីប្រើម្សៅសាប៊ូនេះនៅក្នុងទឹកក្តៅខ្លាំង?

2. ចូរពន្យល់ពីវិធីនៃការដាក់ស្ពូលរាវនៅក្នុងសូកូឡា។

3. ចូររៀបរាប់ពីទង្វើអង់ស៊ីមសម្រាប់ឧស្សាហកម្ម?

4. ចូរបង្ហាញពីភាពខុសគ្នារវាងលំនាំលំហូរឥតឈប់ និងលំនាំរួម?

5. តើលំនាំខាងក្រោមនេះជាលំនាំលំហូរលំហូរឥតឈប់ ឬជាលំនាំរួម?

   ក. ការប្រើសារធាតុជម្រះជីវៈក្នុងម៉ាស៊ីនបោកគក់។

   ខ. ការផលិតនំប៉ុង

   គ. ទង្វើយ៉ាអួ (yoghurt )

6. ចូររៀបរាប់អត្ថប្រយោជន៍ចំនួនពីរនៃលំនាំលំហូរឥតឈប់។

# សំណួរសម្រាប់មេរៀនទី៨

1. ល្បឿនប្រតិកម្មរវាងម៉ាញេស្យូម និង អាស៊ីតក្លរីឌ្រិច រាវអាចវាស់បានដោយប្រើឧបករណ៍ដូចខាងក្រោម ÷




ក- តើគេប្រើ

(i) បំពង់សាកដើម្បីអ្វី?

(ii) សឺរាំងឧស្ម័នដើម្បីអ្វី?

ខ- តើគេត្រូវធ្វើយ៉ាងដូម្តេច ដើម្បីឱ្យប្រតិកម្មអាចចាប់ផ្តើមបាន?

2. ម៉ាញេស្យូមមានប្រតិកម្មជាមួយអាស៊ីតក្លរីឌ្រិចរាវលើស ។ មាឌរបស់អ៊ីដ្រូសែនកកើតត្រូវបានគេកត់ត្រារាល់នាទី ដូចបង្ហាញក្នុងតារាងខាងក្រោម ÷

| រយៈពេល (min) | 0 | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| មាឌ $H_2$ ($cm^3$) | 0 | 14 | 23 | 31 | 38 | 40 | 40 | 40 |

ក- តើអាស៊ីតលើសមានន័យដូចម្តេច?

ខ- ចូរគូសក្រាបតាងលទ្ធផលនេះ ។

គ- ចូរគណនាល្បឿនកកើតអ៊ីដ្រូសែនគិតជា $cm^3$/min ក្នុងកំលុងពេល ÷

(i) នាទីទីមួយ ។

(ii) នាទីទីពីរ ។

(iii) នាទីទីបី ។

ឃ- ហេតុអ្វីបានជាល្បឿនប្រតិកម្មប្រែប្រួលពេលប្រតិកម្មចេះតែប្រព្រឹត្តទៅ? ចូរពន្យល់ ។

ង- តើក្រោយប្រតិកម្ម មាឌអ៊ីដ្រូសែនករកើតបានប៉ុន្មាន $cm^3$?

ច- តើប្រតិកម្មនេះប្រព្រឹត្តទៅចប់ ដោយប្រើរយៈពេលប៉ុន្មាននាទី?

ឆ- ចូរគណនាល្បឿនមធ្យមរបស់ប្រតិកម្មនេះ ។

ជ- តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យប្រតិកម្មនេះប្រព្រឹត្តទៅយឺតជាង ដោយរក្សាបរិមាណលោហៈ និងអាស៊ីត នៅ ដដែល ?

3. ពិសោធន៍អំពីប្រតិកម្មរវាងម៉ាញេស្យូម និងអាស៊ីតក្លរីឌ្រិចរាវត្រូវបានគេធ្វើម្តងទៀត។ ពេលនេះគេប្រើកំហាប់អាស៊ីតខុសពីមុន ដោយទទួលបានលទ្ធផលដូចខាងក្រោម ÷

| រយៈពេល (min) | 0 | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|---|
| V ($H_2$) $cm^3$ | 0 | 22 | 34 | 39 | 40 | 40 | 40 |

ក- ចូរគូសក្រាបតាងលទ្ធផលខាងលើនេះ នៅលើក្រាបនៅក្នុងសំណួរទី២?

ខ- តើប្រតិកម្មក្នុងពិសោធន៍ណាមួយប្រព្រឹត្តទៅលឿនជាង?

គ- តើពិសោធន៍មួយណាមានកំហាប់អាស៊ីតធំជាង? ចូរបញ្ជាក់ពីហេតុផល?

ឃ- នៅក្នុងពិសោធន៍នីមួយៗ មាឌអ៊ីដ្រូសែនកកើតស្មើគ្នា។ តើលទ្ធផលនេះ អាចប្រាប់ អ្នកយ៉ាងដូចម្តេចពីម៉ាសរបស់ ម៉ាញេស្យូមដែលចូលរួមប្រតិកម្ម?

4. ចូរផ្តល់នូវហេតុផលសម្រាប់ការសង្កេតដូចខាងក្រោម ÷

ក- ម្សៅម៉ាញេស្យូមមានប្រតិកម្មលឿនជាងសរសៃ Mg នៅក្នុងប្រតិកម្មជាមួយអាស៊ីតស៊ុលផួរិច។

ខ- អ៊ីដ្រូសែនពែអុកស៊ីតរងប្រតិកម្មបំបែកលឿន ចំពោះមុខអង់ស៊ីមកាតាឡាស។

គ- ប្រតិកម្មរវាងម៉ង់កាណែសកាបូណាត និងអាស៊ីតក្លរីឌ្រិចរាវកាន់តែលឿនកាលណាគេបន្ថែមបរិមាណអាស៊ីតក្លរីឌ្រិចខាប់បន្តិច។

ឃ- ម្សៅស័ង្កសីឆេះក្នុងអុកស៊ីសែនខ្លាំងជាងសន្លឹកស័ង្កសី ។

ង- ប្រតិកម្មរវាងសូដ្យូមត្យូស៊ុលផាត និងអាស៊ីតក្លរីឌ្រិច ប្រើរយៈពេលយូរប្រសិនបើគេធ្វើពិសោធន៍នៅក្នុងផើងទឹកកក។

ច- ស័ង្កសី និងអាស៊ីតស៊ុលផួរិចរាវមានប្រតិកម្មយ៉ាងលឿន នៅពេលគេបន្ថែមសូលុយស្យុងទង់ដែងII ស៊ុលផាតពីរបីតំណក់។ (មិនទាន់រកចម្លើយឃើញ ទុកពិចារណាសិន)

ឆ- កាលណាប៉ះអាស៊ីតគេត្រូវលាងទឹកឱ្យបានច្រើន។

ជ- បំពង់ផ្សែងរថយន្តឆាប់ឡើងច្រែះប្រសិនបើគេប្រើរថយន្តនោះញឹកញាប់។

ឈ- នៅក្នុងកាំជ្រួចប្រើក្នុងពិធីផ្សេងៗ គេប្រើម្សៅម៉ាញេស្យូម តែគេមិនប្រើម៉ាញេស្យូមជាសរសៃទេ។

ញ- នៅក្នុងប្រទេសយើងសត្វដែលងាប់ឆាប់រលួយ ប៉ុន្តែនៅស៊ីបេរី សាកសពដំរីមាំមុតដែលបានងាប់កាលពី 30000ឆ្នាំមុនគេឃើញនៅរក្សាដដែលក្នុងទឹកកក។

ដ- កាលណាអ្នកបរិភោគរបស់ផ្អែមកាន់តែច្រើន ធ្មេញរបស់អ្នកនឹងកាន់តែឆាប់ពុក។

ឋ- ម្ហូបអាហារឆាប់ឆ្អិនកាលណាគេចំអិនដោយបិទគម្របឆ្នាំង ជាងចំហ។

ឍ- សូលុយស្យុងបន្សដែលមានកំហាប់ខាប់ត្រូវបានគេប្រើសម្រាប់លាងជម្រះស្នាមប្រឡាក់។

5. ក- ចូរប្រាប់ឈ្មោះកត្តាបួនយ៉ាងដែលមានឥទ្ធិពលដល់ល្បឿនប្រតិកម្ម និងពណ៌នាពីផលដែលបានមកពីបម្រែបម្រួល

នៃកត្តានីមួយៗ។

ខ- ចូរពន្យល់ពីការទង្គិចរវាងភាគល្អិតនៃកត្តានីមួយៗ។

6. នៅពេលសូដ្យូមត្យូស៊ុលផាតមានប្រតិកម្មជាមួយ អាស៊ីតក្លរីឌ្រិច គេទទួលបានកករ។ នៅក្នុងការសង្កេតមួយ គេបានកត់ត្រារយៈពេលដែលស្នាមខ្មៅងបានរលុបបាត់។ គេប្រើឧបករណ៍ដូចរូបខាងក្រោមនេះសំរាប់ធ្វើពិសោធន៍ ដែលក្នុងនោះមានតែកំហាប់សូលុយស្យុងត្យូស៊ុលផាតទេដែលត្រូវផ្លាស់ប្តូរ។




គេទទួលបានលទ្ធផលដូចខាងក្រោម ÷

| ពិសោធន៍ | A | B | C | D |
|---|---|---|---|---|
| រយៈពេល | 42 | 71 | 124 | 63 |

ក- តើគេវាស់ពេលវេលាយ៉ាងដូចម្តេច ?

ខ- ចូរប្រាប់ឈ្មោះកករដែលកើតឡើង ?

គ- តើអ្វីដែលគេគួរសង្កេតក្នុងពេលធ្វើពិសោធ?

ឃ- តើនៅក្នុងពិសោធន៍ណាមួយដែលប្រតិកម្ម ÷

(i) លឿនបំផុត

(ii) យឺតបំផុត

ង- នៅក្នុងពិសោធន៍ណាមួយដែលសូលុយស្យុងត្យូស៊ុលផាត មានកំហាប់ខាប់ជាងគេ ? តើអ្នកអាចដឹងបានយ៉ាងដូចម្តេច ?

ច- ចូរប្រាប់វិធីពីរយ៉ាងផ្សេងទៀតក្នុងការពន្លឿនល្បឿនប្រតិកម្មនេះ។

7. ទង់ដែងII អុកស៊ីតធ្វើកាតាលីកម្មនៅក្នុងប្រតិកម្ម បំបែកអ៊ីដ្រូសែនពែអុកស៊ីត។ គេថែមអុកស៊ីតនេះ 0,5g ទៅក្នុងកែវមួយដែលមានទឹកអុកស៊ីសែនេ 100 $cm^3$ គេឃើញ មានឧស្ម័នភាយឡើង ។ គេត្រងយកឧស្ម័ននេះ ហើយគេកត់ត្រាមាឌរបស់វារាល់ 10 វិនាទីម្តង ។

គេទទួលបានលទ្ធផលដូចខាងក្រោម ÷

| រយៈពេល (វិនាទី) | 0 | 10 | 20 | 30 | 40 | 50 | 60 | 70 | 80 | 90 |
|---|---|---|---|---|---|---|---|---|---|---|
| មាឌ ($cm^3$) | 0 | 18 | 30 | 40 | 48 | 53 | 57 | 58 | 58 | 58 |

ក- ដូចម្ដេចដែលហៅថាកាតាលីករ?

ខ- ចូរគូសគំនូសតាងឧបករណ៍ដែលសមស្របសម្រាប់ពិសោធន៍នេះ ។

គ- ចូរប្រាប់ឈ្មោះឧស្ម័នដែលកកើត ។

ឃ- ចូរសរសេរសមីការតុល្យការតាងប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ។

ង- ចូរគូសក្រាបតាងលទ្ធផលនេះ ។

ច- ចូររៀបរាប់ពីបម្រែបម្រួលល្បឿនរបស់ប្រតិកម្ម ។

ឆ- តើកំហាប់អ៊ីដ្រូសែនពែអុកស៊ីតប្រែប្រួលដូចម្ដេច នៅពេលដែលប្រតិកម្មដំណើរការ?

ជ- តើធាតុគីមីអ្វីខ្លះមានវត្តមាននៅក្នុងកែវក្រោយពីរយៈពេល 90 វិនាទី?

ឈ- តើម៉ាសទង់ដែង II អុកស៊ីតនៅសល់ប៉ុន្មានក្រោយពីប្រតិកម្មចប់ ?

ញ- ចូរគូសខ្សែកោងនៅលើក្រាបប្រសិនបើគេប្រើ CuO 1,0 g ។

ដ- ចូរប្រាប់ឈ្មោះធាតុគីមីមួយផ្សេងទៀតដែលធ្វើកាតាលីកម្មលើប្រតិកម្មបំបែកនេះ ។

8. គេអាចធ្វើអេតាណុលដោយល្បើងស្ករ ។




ក- តើមានវត្តមានអ្វីនៅក្នុងដំបែនេះដែលបណ្ដាលឱ្យកើតមានល្បើងស្ករ?

ខ- តើសីតុណ្ហភាពមួយណាដែលសមស្របបំផុតសម្រាប់ដំណើរការប្រតិកម្មនេះ?

i. $0\ ^{o}C$　　iii. $25\ ^{o}C$

ii. $10\ ^{o}C$　　iv. $75\ ^{o}C$

ចូរពន្យល់ ។

គ- (i) តើឧស្ម័នអ្វីដែលកកើតនៅក្នុងល្បើងនេះ?

(ii) តើយើងអាចបង្ហាញបានយ៉ាងដូចម្ដេច?

9. អង់ស៊ីមប៉ូលីផេណូស៊ីដាស (polyphenoxidases) ជួយជំរុញប្រតិកម្មអុកស៊ីតកម្មដោយធ្វើឱ្យផ្លែប៉ោមដែលចិតរួចទៅជាពណ៌ត្នោតនៅក្នុងខ្យល់ ។ ចូរពន្យល់នូវការសង្កេតដូចខាងក្រោមនេះ ÷

ក- នៅពេលគេចិតផ្លែប៉ោមភ្លាម សាច់របស់វាមិនប្រែទៅជាពណ៌ត្នោតទេ ។

ខ- ការប្រែពណ៌នេះប្រើរយៈពេលយូរ កាលណាគេដាក់សាច់ផ្លែប៉ោមដែលចិតរួចក្នុងទូទឹកកក ។

គ- គេមិនឃើញចំណិតផ្លែប៉ោមប្រែជាពណ៌ត្នោតទេ ប្រសិនបើគេជ្រលក់វាក្នុងទឹកពុះរយៈពេល ៣០វិនាទីក្រោយ ពីចិតរួចភ្លាម ។

ឃ- ផ្លែប៉ោមដែលគេកិនឱ្យម៉ត់នឹងប្រែ ទៅជាពណ៌ត្នោតឆាប់ជាងផ្លែប៉ោមជាចំណិត ។

ង- ចំណិតផ្លែប៉ោមមិនប្រែទៅជាពណ៌ត្នោតទេ កាលណាគេដាក់ចំណិតដែលចិតភ្លាមទៅក្នុងទឹកក្រូចឆ្មារ ។